ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ថវិកាសង្ខេបឆ្នាំ ២០២២

# BUDGET IN BRIEF FISCAL YEAR 2022

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

នាយកដ្ឋានថវិកានីយកម្ម
អគ្គនាយកដ្ឋានថវិកា

# មាតិកា


ជំពូក១

## សេចក្តីផ្តើម

១.១ បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២២ ........ ៥
១.២ បញ្ហាប្រឈម និងហានិភ័យ ........ ៧
១.៣ អភិក្រម និងគោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០២២ ........ ១១

ជំពូក២

## ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២

២.១ សូចនាករម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២ ........ ១៥
២.២ អតិផរណា និងអត្រាប្តូរប្រាក់ ........ ១៨
២.៣ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជម្រុញកំណើនសេដ្ឋកិច្ច ........ ២០

ជំពូក៣

## ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២

៣.១ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ ........ ២៤
៣.២ គម្រោងចំណូល-ចំណាយថវិការដ្ឋ ........ ២៦
៣.៣ ថវិកាថ្នាក់ជាតិ ........ ៣០
៣.៤ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ........ ៤៣
៣.៥ ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២២ និងស្ថានភាពបំណុល ........ ៤៦

ជំពូក៤

## សេចក្តីសន្និដ្ឋាន

៤ សេចក្តីសន្និដ្ឋាន ........ ៥៣

ជំពូក៥

## ឧបសម្ព័ន្ធ

៥.១ គោលនយោបាយ និងថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ន ........ ៥៦
៥.២ ចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន ........ ៩៦

ជំពូក ១

# សេចក្ដីផ្ដើម



## ១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២២

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំឡើង នៅក្នុងបរិការណ៍ដែលកម្ពុជា កំពុងស្ថិតនៅកណ្តាលនៃវិបត្តិកូវីដ-១៩ នៅឡើយ បន្ទាប់ពី **ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១** និង ការបន្តរីករាលដាលនៃ មេរោគក្លាយពូជបំប្លែងថ្មីជាបន្តបន្ទាប់ ដែលបានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាន ធ្ងន់ធ្ងរ ដល់សុខភាព សង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ក៏ប៉ុន្តែ ក្រោមការដឹកនាំប៉ិនប្រសព្វ, វៃឆ្លាត និងម៉ឺងម៉ាត់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី** កម្ពុជានៅតែ អាចគ្រប់គ្រង សភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យស្ថិតនៅក្នុងកម្រិតដែល អាចគ្រប់គ្រងបាន។ តាមការវាយតម្លៃជាទូទៅ, មនុស្សជាតិនឹងត្រូវរស់នៅ ជាមួយនឹងជំងឺកូវីដ-១៩ នេះ យូរឆ្នាំទៀត តាមគន្លងប្រក្រតីភាពថ្មី។ ក្នុងន័យនេះ កម្ពុជាត្រូវបន្តខិតខំប្រយុទ្ធនឹងជំងឺកូវីដ-១៩ផង និងត្រូវរៀនរស់នៅជាមួយ នឹងជំងឺនេះផង សំដៅឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិពេញលេញ លើគ្រប់វិស័យ ដើម្បីស្តារ និងជំរុញសេដ្ឋកិច្ចឱ្យបន្តស្ថិតនៅលើគន្លងនៃកំណើន ខ្ពស់ និងរស់រវើកឡើងវិញ និយាយជារួម និងនិយាយដោយឡែក គឺស្តារជីវភាព របស់ប្រជាជនទូទៅ ជាពិសេសបងប្អូនដែលបានបាត់បង់នូវឱកាសរកប្រាក់ ចំណូល និងការងារ បណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ទាំងដោយផ្ទាល់ និង ដោយប្រយោល។

ដូចនេះ ថវិកាឆ្នាំ ២០២២ ត្រូវបានរៀបចំឡើង ដើម្បីបន្តការពារអាយុជីវិត ស្តារជីវភាពរស់នៅរបស់ប្រជាជនទូទៅ និងស្តារកិច្ចអភិវឌ្ឍសេដ្ឋកិច្ច- សង្គម កម្ពុជាឡើងវិញ ព្រមទាំងដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ដែលត្រូវបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាល ទី៦ និងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី៤ ពិសេសគឺសន្តិភាព និងស្ថិរភាព នយោបាយ ដែលជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុត និងមិនអាចខ្វះបាន សម្រាប់ ការអភិវឌ្ឍជាតិ និងភាពសុខក្សេមក្សាន្តរបស់ប្រជាជន។ ក្នុងន័យនេះ ថវិកា ឆ្នាំ ២០២២ គឺជាថវិកាសម្រាប់បន្តការប្រយុទ្ធប្រឆាំង និងការកសាងសមត្ថភាព រស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីកម្មថ្មី ដើម្បីបន្តប្រយុទ្ធការពារ

**អាយុជីវិតប្រជាជន រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជនព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅរកការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។**

ទន្ទឹមនេះ, រាជរដ្ឋាភិបាលបាន និងកំពុងបញ្ចេញចំណាយអន្តរាគមន៍យ៉ាងច្រើនទប់ទល់នឹងវិបត្តិនេះ ព្រមជាមួយនឹងការដាក់ចេញឱ្យអនុវត្តនូវ “**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ច កម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**” សំដៅលើកស្ទួយជីវភាពរបស់ប្រជាជនទូទៅដោយឈរលើគោលការណ៍ **ត្រៀមខ្លួនសម្រាប់អ្វីដែលអាក្រក់បំផុតនិងសង្ឃឹមសម្រាប់ អ្វីដែលល្អបំផុត ដើម្បីធានាឱ្យនាវាកម្ពុជាអាចឆ្លងដល់ត្រើយដោយសុវត្ថិភាព ទាំងសម្រាប់ឆ្នាំ ២០២២ និងឆ្នាំ ២០២៣**។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលប្តេជ្ញាបន្តអនុវត្ត និងសម្រេចឱ្យបាននូវអាទិភាពគោលនយោបាយសំខាន់ៗជាសារវ័ន្ត, ដូចមានកំណត់ក្នុង**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**, នៅលើមាគ៌ានៃការកែទម្រង់ស៊ីជម្រៅ និងការជំរុញការអភិវឌ្ឍដោយឈរលើមូលដ្ឋាននៃសមិទ្ធផលជាច្រើន ដែលសម្រេចបានកន្លងមកទាំងខាងនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ពិសេសគឺ **សន្តិភាព និង ស្ថិរភាពនយោបាយ** ដ៏រឹងមាំជាប់មិនដាច់ដែលជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុត និង មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍន៍ជាតិនិងភាពសុខក្សេមក្សាន្តរបស់ប្រជាជន។

ក្នុងន័យនេះ, ថវិកាឆ្នាំ ២០២២ត្រូវបានរៀបចំ និងវិភាជសម្រាប់ការអនុវត្តសកម្មភាពអាទិភាពដែល ត្រូវបានកំណត់ក្នុងកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមានជាអាទិ៍÷ ការទប់ទល់នឹងការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩; ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យស្ទុះងើបឡើងវិញ ដើម្បីបន្តបង្កើតការងារជូនប្រជាជន ជាពិសេសស្រទាប់យុវជន, ផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញ និងជំរុញបង្កើនចំណូលថវិកាជាតិ; ការបន្តអភិវឌ្ឍធនធានមនុស្ស; ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត; ការបន្តអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម; ការកសាងប្រព័ន្ធគាំពារសង្គមរឹងមាំ និងប្រព័ន្ធសុខាភិបាលប្រកបដោយគុណភាព និងមានភាពឆ្លើយតបខ្ពស់; ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ ក៏ដូចជាការ

កែលម្អប្រព័ន្ធអប់រំកាន់តែមានគុណភាពខ្ពស់; និងការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យដែលរាជរដ្ឋាភិបាលបានដាក់ចេញ។ លើសពីនេះទៀត ថវិកាឆ្នាំ ២០២២ ក៏ជាថវិកាដែលត្រូវធានាដល់**ជោគជ័យនៃការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់** ក៏ដូចជា ការបំពេញកាតព្វកិច្ចតំបន់ និងអន្តរជាតិរបស់កម្ពុជា ពិសេសគឺ **ការធ្វើជាម្ចាស់ផ្ទះ** និង **ជាប្រធានអាស៊ាននៅឆ្នាំ ២០២២**។

## ១.២ បញ្ហាប្រឈម និងហានិភ័យ

ដូចបណ្តាប្រទេសនានានៅលើសកលលោកដែរ ឆ្នាំ ២០២០ និង២០២១ គឺជាឆ្នាំដ៏លំបាកបំផុតក្នុងប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជាដោយសារផលប៉ះពាល់អវិជ្ជមាន បញ្ហាប្រឈម និងហានិភ័យជាច្រើនដែលមិនធ្លាប់មានពីមុនមកបណ្តាលមកពីជំងឺកូវីដ-១៩។ ជំងឺនេះ មិនត្រឹមតែបានធ្វើឱ្យធ្លាក់ខ្លួនឈឺ និងឆក់យកអាយុជីវិតប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យកំណើនសេដ្ឋកិច្ចធ្លាក់ចុះ អាជីវកម្មគ្រប់វិស័យត្រូវប៉ះពាល់តិចឬច្រើន ហើយខ្លះទៀតត្រូវបិទទ្វារ ឬផ្អាកសកម្មភាព ក្នុងខណៈដែលវិស័យអប់រំ ក៏ប៉ះពាល់ខ្លាំងដូចគ្នាដោយសារការបិទសាលារៀន ទោះបីសិស្សនៅតែអាចបន្តសិក្សាតាមអនឡាញក្តី។ ជាងនេះទៅទៀត ឱកាសរកប្រាក់ចំណូល ការងារ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនត្រូវទទួលរងផលប៉ះពាល់ខ្លាំង ជាពិសេសអាជីវករតូចតាច កម្មករនិយោជិត និងក្រុមជនងាយរងគ្រោះ។ ជាមួយគ្នានេះ ការរាតត្បាតនៃជំងឺកូវីដ-១៩ ក៏បានបង្អួចបង្អាក់ដល់សន្ទុះនៃការអនុវត្តការងារកែទម្រង់របស់រាជរដ្ឋាភិបាល ក៏ដូចជាការអនុវត្តការងាររបស់ក្រសួងស្ថាប័ននានាផងដែរ ក្នុងខណៈដែលកម្លាំងជួរមុខក្នុងការប្រយុទ្ធនឹងជំងឺនេះ កាន់តែហត់នឿយ ហើយធនធានរបស់រដ្ឋក៏កាន់តែស្តួចស្តើង ដោយសារបន្ទុកចំណាយក្នុងការប្រយុទ្ធនឹងជំងឺនេះចេះតែកើនឡើងឥតឈប់ក្នុងពេលចំណូលថវិកាជាតិមានការថមថយ។

ក្រៅពីចំណាយក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលក៏មានតម្រូវការចំណាយអន្តរាគមន៍ ផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ចផងដែរ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងទ្រទ្រង់សកម្មភាពអាជីវកម្មក្នុង ស្រុក ដូចជាការឧបត្ថម្ភសាច់ប្រាក់ដល់កម្មករ-និយោជិតដែលត្រូវបានព្យួរការងារ និងការអនុវត្តកម្មវិធី

ជំនួយសង្គមមួយចំនួនផ្សេងទៀត ដូចជា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ព្រមទាំងអ្នកដែលត្រូវធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រដោយសារផលប៉ះពាល់ពីជំងឺកូវីដ-១៩ កម្មវិធីសាច់ប្រាក់ ពលកម្ម និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំក្នុងគ្រួសារក្រីក្រជាដើម។ ជាងនេះទៅទៀត ជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ តែថែមទាំងបានបង្កើតជាបច្ច័យអវិជ្ជមាន និងបញ្ហាជារចនាសម្ព័ន្ធដែលកំពុងប្រឈមស្រាប់ ក្នុងរយៈពេលមធ្យមខាងមុខផង និងអាចប៉ះទង្គិចដល់គន្លងអភិវឌ្ឍន៍របស់កម្ពុជា ក្នុងរយៈពេលវែងផងដែរ ជាពិសេសការឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួនក្នុងការប្រែក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០។

តាមការព្យាករណ៍ ថ្វីត្បិតតែសេដ្ឋកិច្ចពិភពលោកចាប់ផ្ដើមងើបឡើងវិញនៅក្នុងឆ្នាំ ២០២១នេះ និង ក្នុងឆ្នាំ ២០២២ខាងមុខក្ដី ក៏ប៉ុន្តែផលប៉ះពាល់អវិជ្ជមានបណ្ដាលមកពីជំងឺកូវីដ-១៩ នៅមិនទាន់ថមថយ នៅឡើយ។ មួយវិញទៀត កម្លាំង និងល្បឿននៃការងើបឡើងវិញនេះទៀតសោតក៏នឹងមានកម្រិតខុសគ្នាពីប្រទេសមួយទៅប្រទេសមួយដោយសារគម្លាតនៃអត្រាចាក់វ៉ាក់សាំង ការអនុវត្តនូវវិធានការអន្តរាគមន៍ទាំង ខាងផ្នែកសុខាភិបាល និងទាំងផ្នែកសេដ្ឋកិច្ច តាមរយៈប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុរួមទាំងប្រសិទ្ធភាពនៃការអនុវត្តវិធានការគាំទ្រផ្សេងទៀត ជាពិសេសសមត្ថភាពសម្របខ្លួន ទៅនឹងវិបត្តិនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចមុនវិបត្តិ។ ពិតណាស់ថា ទោះបីជាវិបត្តិនៃជំងឺកូវីដ-១៩អាចនឹងធូរស្រាលនាពេលខាងមុខដោយសារសម្ទុះនៃការទទួលបាន និងការពង្រីកវិសាលភាពនៃការចាក់វ៉ាក់សាំងតាមប្រទេសនីមួយៗក្ដី ប៉ុន្តែពិភពលោកទាំងមូលនៅតែអាចប្រឈមនឹងហានិភ័យនៃការមកដល់នូវរលកថ្មីបង្កឡើងដោយមេរោគបំប្លែងខ្លួនថ្មីៗទៀត។

ឆ្លងកាត់បទពិសោធន៍នៃការគ្រប់គ្រងវិបត្តិនៃជំងឺកូវីដ-១៩ ជាងមួយឆ្នាំកន្លងមកនេះ កម្ពុជាពិតជា មិនអាចពឹងផ្អែកតែលើខ្លួនឯងទាំងស្រុង ហើយកាត់ផ្ដាច់បិទប្រទេស ពីក្របខ័ណ្ឌតំបន់ និងសកលលោក ដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩ និងជំរុញការងើបឡើងនូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចបានឡើយ។

ដូច្នេះដោយសារសេដ្ឋកិច្ចកម្ពុជាមានការបើកចំហរខ្លាំង ដូចបានគូសបញ្ជាក់ខាងលើ កម្ពុជាក៏អាចងាយនឹងទទួលរងនូវបច្ច័យអវិជ្ជមានមួយចំនួនបន្ថែមទៀត ពីស្ថានភាពភូមិសាស្ត្រនយោបាយក្នុងតំបន់ និងពិភពលោក ដែលកាន់តែឡើងកំដៅ និងកាន់តែវិវត្តស្មុគស្មាញជាងមុន បណ្តាលមកពីការប្រកួតប្រជែងរវាងប្រទេសមហាអំណាច ជាពិសេសសង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា ព្រមទាំងនិន្នាការធ្លាក់ចុះនៃពហុភាគីនិយម និងនិន្នាការកើនឡើងនៃឯកតោភាគីនិយម ប្រជានិយម និងការគាំពារនិយម រួមទាំងចេតនាជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងពីសំណាក់ប្រទេសមួយចំនួនទៀតក្រោមរូបភាពផ្សេងៗ។ ជាមួយគ្នានេះ ការប្រែប្រួលអាកាសធាតុដែលជាបញ្ហាប្រឈមរបស់មនុស្សជាតិ និងប្រទេសនីមួយៗ ក៏កាន់តែអាក្រក់ និងមានសភាពធ្ងន់ធ្ងរ ជាងមុនជាលំដាប់ ហើយក្នុងករណីខ្លះការប្រែប្រួលនៃអាកាសធាតុក៏បានបង្កើតជាជំងឺផ្សេងៗឥតឈប់ឈរ ផងដែរ។

ក្នុងន័យនេះ កម្ពុជាត្រូវបន្តគ្រប់គ្រងសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩ ឱ្យបានល្អប្រសើរ ក្នុងស្មារតីបុរេសកម្មជាប់ជាប្រចាំ ជាពិសេសការពង្រឹងប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីកសាង មូលដ្ឋានចាំបាច់សម្រាប់ការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ និងអាចមានលទ្ធភាពគ្រប់គ្រាន់ទប់ទល់ការវាយលុកពីជំងឺកូវីដ-១៩ ក្នុងករណីមានការឆ្លងរាលដាលទ្រង់ទ្រាយធំចូលក្នុងសហគមន៍។ និន្នាការថ្មីៗនេះ បានបង្ហាញថា ប្រទេសណាដែលគ្រប់គ្រងវិបត្តិនៃជំងឺកូវីដ-១៩បានល្អ ជាពិសេសចាក់វ៉ាក់សាំងបានលឿន ប្រទេសនោះអាចចាប់ផ្តើមបើកសេដ្ឋកិច្ចរបស់ខ្លួនបានឆាប់រហ័សតាមនោះដែរ។ ដូច្នេះកម្ពុជាដែលកំពុងស្ថិតក្នុងចំណោមប្រទេសដែលឈានមុខគេ ក្នុងដំណើរឆ្ពោះទៅរកការបង្កើតភាពស៊ាំសហគមន៍កាលពីដំណាច់ឆ្នាំ ២០២១ នឹងមិនត្រឹមតែហុចលទ្ធភាពដល់កម្ពុជាឱ្យអាចដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញជាបណ្តើរៗ តាមគន្លងប្រក្រតីថ្មីបានឆាប់ប៉ុណ្ណោះទេ តែថែមទាំងអាចបង្កើតបានជាកាលានុវត្តភាពដ៏ពិសេស ដើម្បីដណ្តើមទំនុកចិត្តពីអ្នកវិនិយោគក៏ដូចជាភ្ញៀវទេសចរបរទេស ស្របពេលដែលសេដ្ឋកិច្ច របស់បណ្តាប្រទេសជាដៃគូពាណិជ្ជកម្មធំៗរបស់កម្ពុជា ចាប់ផ្តើមងើបឡើងវិញ ហើយប្រទេសជាគូប្រកួតប្រជែងកម្ពុជាមានភាពយឺតយ៉ាវក្នុងការអនុវត្តយុទ្ធសាស្ត្រវ៉ាក់សាំង។

ទោះបីជាយ៉ាងណា ជំងឺកូវីដ-១៩អាចនឹងអូសបន្លាយយូរឆ្នាំទៀត ហើយការងារប្រយុទ្ធនឹងជំងឺនេះ ក៏ពាក់ព័ន្ធច្រើនវិស័យលើសពីវិស័យសុខភាពសាធារណៈតែមួយមុខ។ ដូច្នេះកម្ពុជាក៏ត្រូវបន្តគ្រប់គ្រងវិស័យ ហិរញ្ញវត្ថុសាធារណៈឱ្យបានល្អប្រសើរ ក្នុងពេលដ៏លំបាកនេះ និងត្រូវខិតខំបង្កើតនូវឧបករណ៍ហិរញ្ញប្បទានថ្មីៗ បន្ថែមទៀត ដើម្បីអាចមានធនធានគ្រប់គ្រាន់សម្រាប់ធនធាននេះទាំងសម្រាប់បន្តប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងស្តារសេដ្ឋកិច្ចនិងជីវភាពប្រជាជន។ ទន្ទឹមនឹងនេះដែរ កម្ពុជាត្រូវបន្តពង្រឹងសមត្ថភាពផ្ទៃក្នុងជាប់ជាប្រចាំ ជាពិសេសសមត្ថភាពស្ថាប័នសាធារណៈ និងអភិបាលកិច្ច ឱ្យកាន់តែរឹងមាំ មានភាពឆ្លើយតបប្រកប ដោយប្រសិទ្ធភាព និងមានភាពធន់ខ្ពស់ទៅនឹងវិបត្តិនានា រួមទាំងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិនាពេលអនាគត។

ក្នុងកាលៈទេសៈនេះ កម្ពុជាត្រូវខិតខំទ្វេដង ដើម្បីប្រើប្រាស់កាលានុវត្តភាពនេះឱ្យអស់សក្តានុពល និងត្រូវប្រែក្លាយវិបត្តិនៃជំងឺកូវីដ-១៩ ទៅជាឱកាសជាងពេលណាៗទាំងអស់ ដើម្បីជំរុញអនុវត្តកិច្ចការកែទម្រង់គ្រប់ការដ្ឋានឱ្យមានលក្ខណៈស៊ីជម្រៅ ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ ដើម្បីអាចវះកាត់បញ្ហាជារចនាសម្ព័ន្ធនានា សំដៅធ្វើឱ្យកាន់តែប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្ម និងបរិស្ថានវិនិយោគ សម្រាប់ទាក់ទាញបន្ថែមនូវការវិនិយោគ និងធុរកិច្ច ដែលអាចហូរចេញពីតំបន់មានជម្លោះពាណិជ្ជកម្ម និងមានអស្ថេរភាពនយោបាយ ព្រមទាំងការផ្លាស់ប្តូរខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ចូលមកកម្ពុជាផង និងម្យ៉ាងទៀត ដើម្បីជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច សម្រាប់បង្កើតការងារជូនប្រជាជនផង ព្រមទាំងការលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់កម្ពុជាផងដែរ។ ទន្ទឹមនឹងនេះ កម្ពុជាត្រូវខិតខំជំរុញការធ្វើបរិវត្តកម្មឌីជីថលឱ្យបានលឿន តាមរយៈការជំរុញអនុវត្តនូវ**ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥** ដើម្បីជួយជំរុញសន្ទុះកំណើន និងការបង្កើតនូវចន្ទល់កំណើនសេដ្ឋកិច្ចថ្មី ជំនួសឱ្យចន្ទល់ចាស់ដែលមានសញ្ញាថមថយជាបណ្តើរៗ ក៏ដូចជាការកាត់បន្ថយផលប៉ះពាល់ ឬបច្ច័យអវិជ្ជមានពីបច្ចេកវិទ្យាឌីជីថលឱ្យស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។

**រូបភាពទី១ ÷** បញ្ហាប្រឈម និងហានិភ័យ




## ១.៣. អភិក្រម និងគោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០២២

ថវិកាឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងដោយផ្អែកលើ អភិក្រមគ្រឹះជាយុទ្ធសាស្ត្រ និងគោលការណ៍ បច្ចេកទេសសំខាន់ៗ ដូចខាងក្រោម÷

### ក. អភិក្រមគ្រឹះជាយុទ្ធសាស្ត្រសំខាន់ៗ៥÷

១. ទប់ទល់ការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ ហើយបន្សាំខ្លួនរស់នៅជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីកម្មថ្មី

២. អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ

២០២១-២០២៣ ដើម្បីធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៤,៨% និងបន្តបង្កើតការងារជូនប្រជាជន ជាពិសេសស្រទាប់យុវជន ព្រមទាំងផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញ និងបង្កើនចំណូលថវិកាជាតិ

៣. ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងបាននូវអតិផរណា និងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ

៤. បន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច សំដៅធានាស្ថិរភាពកំណើន គាំទ្រដល់ការស្តារសេដ្ឋកិច្ច និងឆ្លើយតបតាមការសន្យាទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ព្រមទាំងពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និងសមត្ថភាពនៃវិស័យសាធារណៈ ក្នុងគោលដៅពង្រីកវិសាលភាព និងពង្រឹងគុណភាពនៃសេវាសាធារណៈ និងសេវាយុត្តិធម៌

៥. ធានាអនុវត្តឱ្យបានជោគជ័យនូវរបៀបវារៈនៃការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ តាមរយៈការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក៏ដូចជាការបំពេញកាតព្វកិច្ច តំបន់ និងអន្តរជាតិរបស់កម្ពុជា ជាពិសេសក្នុងនាមជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន។

## ខ. គោលការណ៍បច្ចេកទេសសំខាន់ៗ៧៖

១. ការធានាចីរភាព និងសមិទ្ធកម្មនៃចំណូល,

២. ការធ្វើវិចារណកម្មលំដាប់អាទិភាព,

៣. ការយកចិត្តទុកដាក់លើមនុស្ស,

៤. ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/ សកម្មភាព,

៥. ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត,

៦. ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា,

៧. ការរក្សាតុល្យភាព និងចីរភាពថវិកា។

## រូបភាពទី២ ÷ គោលការណ៍គ្រឹះយុទ្ធសាស្ត្រ និងគោលការណ៍បច្ចេកទេស

### ក. អាទិភាពគ្រឹះជាយុទ្ធសាស្ត្រ សំខាន់ៗ ៥ ចំណុច

១. ទប់ទល់ការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងរស់នៅជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីកម្មថ្មី

២. អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ច

៣. ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងបាននូវអតិផរណា និងស្ថិរភាពអត្រាប្តូរប្រាក់

៤. បន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល

៥. ធានាអនុវត្តឱ្យបានជោគជ័យនូវរបៀបវារៈនៃការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ

### ខ. គោលការណ៍បច្ចេកទេស សំខាន់ៗ ៧ ចំណុច

១. ការធានាចីរភាព និងសមិទ្ធកម្មនៃចំណូល

២. ការធ្វើវិចារណកម្មលំដាប់អាទិភាព

៣. ការយកចិត្តទុកដាក់លើមនុស្ស

៤. ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព

៥. ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត

៦. ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា

៧. ការរក្សាតុល្យភាព និងចីរភាពថវិកា។

ជំពូក ២

# ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២



## ២.១ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២

តាមការវាយតម្លៃពាក់កណ្ដាលឆ្នាំកន្លងមកនេះ សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០២១ ត្រូវបានប៉ាន់ស្មានថា មានកំណើនក្នុងអត្រា២,៤%។ ការប៉ាន់ស្មានអត្រាកំណើននេះ គឺមាននិន្នាការស្រដៀងគ្នាទៅនឹងការវាយតម្លៃរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗក្នុងរង្វង់ប្រមាណ២,០%។ សម្រាប់ឆ្នាំ ២០២២ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងអត្រា៤,៨% ដែលធ្វើឱ្យ ផ.ស.ស. ថ្លៃបច្ចុប្បន្នស្ថិតក្នុងរង្វង់១២៤ ១៦២ប៊ីលានរៀល ឬសមមូលនឹងប្រមាណ ៣០ ៥៤៤លានដុល្លារអាម៉េរិក ស្របពេលដែល ផ.ស.ស. សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៨៤២ដុល្លារអាម៉េរិក បើធៀបនឹង ១ ៧៣០ដុល្លារអាម៉េរិកក្នុងឆ្នាំ ២០២១។ កំណើននេះគាំទ្រដោយការបន្តកើនឡើងនៃវិស័យសេដ្ឋកិច្ចសំខាន់ៗ ដូចខាងក្រោម៖

**ទី១**

វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងអត្រា ៧,៧% ក្នុងឆ្នាំ ២០២២ ពីកំណើន ៥,៧% ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់ត្រូវបានរំពឹងថានៅបន្តសម្រេចបានកំណើនទាប។ អនុវិស័យកាត់ដេរ ត្រូវបានរំពឹងថានឹងបន្តកើនឡើង ដោយសារការរំពឹងទុកភាពល្អប្រសើរនៃតម្រូវការខាងក្រៅ ជាពិសេស ទីផ្សារសហរដ្ឋអាម៉េរិក និងចិន ស្របជាមួយការរំពឹងទុកការបង្វែររោងចក្រពីប្រទេសមីយ៉ាន់ម៉ា គួបផ្សំនឹងការដាក់ចេញនូវ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២១-២០២៥"។ ជាមួយគ្នានេះ អនុវិស័យកាត់ដេរក៏ត្រូវបានរំពឹងថានឹងអាចជួបប្រទះនូវហានិភ័យមួយចំនួន ជាពិសេសការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ និងការផ្ទុះជាទ្រង់ទ្រាយធំក្នុងរោងចក្រ ដែលអាចបណ្ដាលឱ្យប៉ះពាល់ដល់សកម្មភាពផលិតកម្ម និងការផ្គត់ផ្គង់ បើទោះបីតម្រូវការខាងក្រៅនៅបន្តមានភាពល្អប្រសើរយ៉ាងណាក្ដី។ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរត្រូវបានរំពឹងថានៅរក្សាបានកំណើនរឹងមាំ ដោយសារមួយផ្នែកគឺការបន្ត កើនឡើងនៃតម្រូវការខាងក្រៅ និងមួយផ្នែកទៀតដោយសារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលអាចបន្តជំរុញការនាំចេញលើផលិតផលសំខាន់ៗ រួមមាន គ្រឿងសង្ហារិម, ស្បែកសត្វមានរោម, ក្ដារកុងប្លាកេ, ឈើមូល ឬឈើអារ (timber) និងឈើ (veneer), វត្ថុសម្រាប់

ជាងសំណង់ធ្វើពីប្លាស្ទិក, សូឡា, គ្រឿងអេឡិចត្រូនិក និងភាគបំណែក, ខ្សែភ្លើង និងបង្គុំខ្សែភ្លើង, កៅស៊ូ, ចេក, ស្ករស, ដំឡូងមី, ស្វាយ និងកសិផលផ្សេងៗជាដើម។ ទន្ទឹមនេះ ការដាក់ចេញនូវ “ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា” នឹងអាចរួមចំណែកបង្កើនបរិយាកាសវិនិយោគឱ្យកាន់តែមានភាពទាក់ទាញ និងប្រសើរជាងមុន។ ដោយឡែក អនុវិស័យសំណង់ ត្រូវបានរំពឹងថានឹងបន្តងើបក្នុងល្បឿនយឺត ដោយសារការរំពឹងទុកការងើបឡើងវិញសន្សឹមៗ នូវទំនុកចិត្តវិនិយោគ និងរំហូរទុនវិនិយោគ ជាពិសេសសកម្មភាពសំណង់បម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ស្របពេលដែលសកម្មភាពសំណង់លំនៅឋានក៏ត្រូវបានរំពឹងថានៅបន្តរក្សាកំណើន ប៉ុន្តែស្ថិតក្នុងកម្រិតទាប។

**ទី២**

វិស័យសេវាកម្មត្រូវបានព្យាករថានឹងបន្តកើនឡើងក្នុងអត្រា ៤,១% ក្នុងឆ្នាំ ២០២២ ពីកំណើនត្រឹម ០,៣% ក្នុងឆ្នាំ ២០២១ ដោយសារការងើបឡើងវិញសន្សឹមៗនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងវិស័យគាំទ្រទេសចរណ៍ផ្សេងទៀត។ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋានត្រូវបានរំពឹងថានឹងងើបឡើងវិញ ប៉ុន្តែស្ថិតក្នុងកម្រិតទាប ទាំងទំហំ និងអត្រាកំណើន, ដោយសារការរំពឹងទុកការងើបឡើងវិញក្នុងល្បឿនយឺតនៃភ្ញៀវទេសចរអន្តរជាតិ ខណៈដែលចំនួនភ្ញៀវទេសចរជាតិត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងសម្ទុះលឿនជាងនៅពេលដែលការរាតត្បាតក្នុងសហគមន៍មានការស្រាកស្រាន្ត និងគ្រប់គ្រងបាន។ អនុវិស័យលក់ដុំ-រាយត្រូវបានព្យាករថានឹងបន្តកើនឡើង ប៉ុន្តែក្នុងអត្រាទាបជាងកំណើនមុនពេលមានវិបត្តិ ដោយសារឥទ្ធិពលថមថយចំណូលរបស់ប្រជាជន ស្របពេលដែលអនុវិស័យសំខាន់ៗ ដែលជាប្រភពចំណូលរបស់ប្រជាជនត្រូវបានរំពឹងថានឹងងើបឡើងសន្សឹមៗ។ អនុវិស័យអចលនទ្រព្យមាននិន្នាការដូចគ្នាទៅនឹងវិស័យសំណង់ដែលត្រូវបានរំពឹងថាបន្តកំណើនទាប ដោយសារការរំពឹងទុកនៃការងើបឡើងជាបណ្តើរៗនូវទំនុកចិត្តវិនិយោគនិងរំហូរវិនិយោគទុនពីបរទេស។ អនុវិស័យដឹកជញ្ជូននិងគមនាគមន៍ត្រូវបានព្យាករថានឹងបន្តកើនឡើងដោយសារការរំពឹងទុកនៃការងើបឡើងវិញនូវសកម្មភាពដឹកជញ្ជូន ស្របពេលនឹងការងើបឡើងវិញនៃអនុវិស័យគាំទ្រដល់សកម្មភាពដឹកជញ្ជូន និងនិន្នាការនៃការបន្តកើនឡើងនូវការប្រើប្រាស់អ៊ីនធឺណិត គួបផ្សំនឹងការដាក់ចេញនូវ “**ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**” ដែល

នឹងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងលើកកម្ពស់ការប្រើប្រាស់ឌីជីថលនៅកម្ពុជា។

**ទី៣** វិស័យកសិកម្ម ត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងអត្រាទាប ១,១% ក្នុងឆ្នាំ ២០២២ បើប្រៀបធៀបនឹងកំណើន ១,៤% ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកនៃការបន្តកំណើនល្អប្រសើរនៃអនុវិស័យដំណាំ និង អនុវិស័យចិញ្ចឹមសត្វ។ អនុវិស័យដំណាំត្រូវបានរំពឹងថានឹងនៅបន្តកំណើនល្អប្រសើរ ដោយសារការរំពឹងទុកកំណើនល្អប្រសើរនៃការនាំចេញផលិតផលកសិកម្ម ជាពិសេសដំណាំរួមផ្សំនិងឧស្សាហកម្មដែលនឹងបន្តជំរុញ ដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី គួបផ្សំជាមួយនឹងការបង្កើនការវិនិយោគរបស់រាជរដ្ឋាភិបាល ជាពិសេសការផ្តល់ហិរញ្ញប្បទានក្នុងការជំរុញផលិតកម្មក្នុងស្រុក។ អនុវិស័យចិញ្ចឹមសត្វត្រូវបានរំពឹងថានឹងនៅបន្តរក្សាកំណើនខ្ពស់ ដោយសារការរំពឹងទុកការបន្តកើនឡើងនៃផលិតកម្មជ្រូក គួបផ្សំនឹងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល និងការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានា។ ដោយឡែក អនុវិស័យនេសាទត្រូវបានរំពឹងថានឹងមានកំណើនថមថយធៀបនឹងឆ្នាំ ២០២១ ដោយសារការរំពឹងទុកការថមថយផលិតកម្មវារីវប្បកម្មបណ្តាលមកពីការរាំងស្ទះ ក៏ដូចជាភាពលំបាកក្នុងការចូលមកកាន់ទីផ្សារផ្គត់ផ្គង់។

**ក្រាហ្វិកទី១ ÷** កំណើន ផ.ស.ស. តាមវិស័យឆ្នាំ ២០១០-២០២២




*ប្រភពៈវិទ្យាស្ថានជាតិស្ថិតិ (២០១៥-២០២០) និងការប៉ាន់ស្មាននិងការព្យាករណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១-២០២២)*

**តារាងទី១ ៖** សូចនាករសំខាន់ៗនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២

| សូចនាករសេដ្ឋកិច្ច | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ១០៩ ០៦២ | ១១៥ ២១៣ | ១២៤ ១៦២ |
| កំណើននៃ ផ.ស.ស. តាមថ្លៃថេរ (%) | -៣,១ | ២,៤ | ៤,៨ |
| ផ.ស.ស. សម្រាប់មនុស្សម្នាក់(ដុល្លារអាម៉េរិក) | ១ ៦៥៣ | ១ ៧៣០ | ១ ៨៤២ |
| អតិផរណា (អត្រាមធ្យមប្រចាំឆ្នាំ) (%) | ២,៩ | ៣,៤ | ២,៨ |
| អត្រាប្តូរប្រាក់ (ដុល្លារអាម៉េរិក/ រៀល) | ៤ ០៨០ | ៤ ០៦៥ | ៤ ០៦៥ |
| សមតុល្យគណនីចរន្ត (% នៃ ផ.ស.ស.) | -៨,១ | -១៤,៩ | -១៣,១ |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាម៉េរិក) | ២១ ៣៣៤ | ២១ ៦១៤ | ២២ ១២០ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ១១,៦ | ១០,៩ | ១០,១ |

*ប្រភព៖ ការប៉ាន់ស្មានឆ្នាំ ២០២០ដោយវិទ្យាស្ថានជាតិស្ថិតិ និងការព្យាករណ៍ឆ្នាំ ២០២១-២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ ២០២១*

## ២.២. អតិផរណា និងអត្រាប្តូរប្រាក់

**អតិផរណាមធ្យមប្រចាំឆ្នាំ** ត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ក្នុងអត្រា ២,៨% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកការវិលត្រលប់ទៅរកនិន្នាការធម្មតាវិញនៃថ្លៃម្ហូបអាហារ។ ចំណែកឯ **អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាម៉េរិក** ត្រូវបានប៉ាន់ស្មានថានឹងនៅតែបន្តមានស្ថិរភាពក្នុងរង្វង់ **៤០៦៥ រៀល** ក្នុងមួយដុល្លារអាម៉េរិកក្នុងឆ្នាំ ២០២២ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំនឿទុកចិត្តពីសំណាក់សាធារណជនលើ ការប្រើប្រាស់ប្រាក់រៀលតាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។ **ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ)** ត្រូវបានព្យាករថានឹងរួមតូចបន្តិច

មកត្រឹម ១៣,១% នៃ ផ.ស.ស. ដោយសារការរំពឹងនៃការងើបឡើងវិញសន្សឹមៗនូវការនាំចេញ និងវិស័យទេសចរណ៍។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងកើនឡើងដល់ ២០ ១២០ លានដុល្លារអាម៉េរិក និងធានាការនាំចូលបាន **១០,១ ខែ** ដោយហេតុថាការនាំចូលរបស់កម្ពុជាក៏នឹងងើបឡើងបន្តិចវិញ។

### ក្រាហ្វិកទី២ ÷ អត្រាអតិផរណា និងអត្រាប្តូរប្រាក់ឆ្នាំ ២០១០-២០២២




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

### ក្រាហ្វិកទី៣ ÷ ទុនបម្រុងអន្តរជាតិ និងផលធៀបចំនួនខែនៃការនាំចូលឆ្នាំ ២០១០-២០២២




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

ជារួម បើទោះបីជាសេដ្ឋកិច្ចក្នុងឆ្នាំ ២០២២ ត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងអត្រាដូចខាងលើ ក៏ដោយ, កម្ពុជាក៏ត្រូវជួបបញ្ហាប្រឈម និងហានិភ័យមួយចំនួនទាំងក្នុង និងក្រៅប្រទេស ដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច និងបង្កភាពរអាក់រអួលដល់កិច្ចអភិវឌ្ឍន៍ជារួម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជានឹងជំរុញការអនុវត្ត **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣** ដែលរាជរដ្ឋាភិបាលបានដាក់ចេញក្នុងឆ្នាំ ២០២១ ព្រមជាមួយនឹងការដាក់ឱ្យអនុវត្តនូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលាតាមរយៈគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយជារចនាសម្ព័ន្ធ ក្នុងគោលបំណងរក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជំរុញកំណើនឡើងវិញ។

## ២.៣ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ច

ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៤,៨% ក្នុងបរិបទនៃការកើនឡើងនូវភាពមិនប្រាកដប្រជាទាំងក្នុង និងក្រៅប្រទេស, **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣** ដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់អោយអនុវត្តបានកំណត់នូវចក្ខុវិស័យ÷ **ពង្រឹងការកសាងមាតិ និងជីវភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយភាពរឹងមាំ និងចាប់យកកាលានុវត្តភាពទាំងក្នុង និងក្រៅប្រទេស ដើម្បីកែលម្អមូលដ្ឋានសេដ្ឋកិច្ចជាតិឱ្យមានភាពប្រកួតប្រជែង និងពិពិធកម្មខ្ពស់ ព្រមទាំងលើកកម្ពស់សុខុមាលភាព រស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាឱ្យស្របទៅនឹងប្រក្រតីភាពថ្មីនៃការអភិវឌ្ឍ។** ដើម្បីឆ្លើយតបនឹងចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានកំណត់គោលបំណងគឺដើម្បីស្តារសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខ និងរយៈពេលមធ្យមឱ្យត្រឡប់ទៅកំណើនសក្តានុពល និងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្នក្នុងរយៈពេលវែង។ ដើម្បីសម្រេចគោលបំណងនេះ គោលដៅចំនួន៤ត្រូវបានកំណត់÷

- ស្តារវិស័យជាចន្ទល់នៃសេដ្ឋកិច្ច ដែលទទួលរងនូវផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ ដោយដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ និងលុបបំបាត់កត្តារាំងស្ទះគន្លឹះៗតាមវិស័យ ឱ្យខាងតែបាន គួបផ្សំនឹងការចាប់យកវិស័យសក្តានុពលនៃកំណើនសេដ្ឋកិច្ច,
- កែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ សំដៅកសាងមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់កំណើន ពិពិធកម្ម និងភាពប្រកួតប្រជែង,
- ពង្រឹងភាពធន់ តាមរយៈការត្រៀមខ្លួន និងការឆ្លើយតប ដើម្បីធានាបាននូវចីរភាព និងបរិយាប័ន្ន នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, និង
- សម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចតាមរយៈការលើកកម្ពស់យន្តការសារពើពន្ធ, ធានាស្ថិរភាពរូបិយវត្ថុ, ពង្រឹងសមតុល្យពាណិជ្ជកម្ម ក៏ដូចជាគិតគូរទៅលើយន្តការហិរញ្ញប្បទាន ជាដើម។

ការស្តារសេដ្ឋកិច្ចឡើងវិញ គឺទាមទារឱ្យមានការដាក់ចេញនូវវិធានការគោលនយោបាយដែលមានភាពច្នៃប្រឌិតខ្ពស់ គ្រប់ជ្រុងជ្រោយ និងមានធនធានគ្រប់គ្រាន់ សម្រាប់អនុវត្ត ដើម្បីអាចអូសកំណើនសេដ្ឋកិច្ចឱ្យត្រឡប់ទៅខិតជិតកំណើនជាសក្តានុពលឡើងវិញ។ ទន្ទឹមនេះ យុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើននេះ មិនត្រឹមតែផ្តោតទៅលើការស្តារសេដ្ឋកិច្ចនិងជីវភាពប្រជាជនឱ្យបានឆាប់រហ័សប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងដើម្បីធានាឱ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌, និរន្តរភាព, និង បរិយាប័ន្នក្នុងរយៈពេលវែងផងដែរ ដោយឈរលើសសរស្តម្ភចំនួន ៣ (ឬហៅថា 3Rs) ដូចខាងក្រោម÷

**សសរស្តម្ភទី១-ការស្តារ (Recovery) ÷** តាមរយៈការកសាងមូលដ្ឋានរឹងមាំសម្រាប់ស្តារសេដ្ឋកិច្ចឱ្យវិលទៅស្ថិតលើមាគ៌ានៃកំណើនឡើងវិញ ដោយផ្តោតលើការធានាសុវត្ថិភាព, ការគ្រប់គ្រងផលប៉ះពាល់, ការរក្សាលំនឹង និងការរស់ឡើងវិញនៃធុរកិច្ចដែលមានសក្តានុពល ជាពិសេសក្នុងវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំង និងការបង្កើតការងារបន្ថែមឱ្យបានច្រើន និងឆាប់រហ័ស សំដៅជំរុញការងើបឡើងវិញនូវជីវភាពប្រជាជន ក៏ដូចជាផ្នែកអាជីវកម្មនិងធុរកិច្ច និងសង្គមទាំងមូល។

**សសរស្តម្ភទី២-ការកែទម្រង់ (Reform)÷** តាមរយៈការបន្តដាក់ចេញវិធានការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ ដែលរួមមាន ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាស និង កិច្ចសម្រួលពាណិជ្ជកម្ម សម្រាប់ការវិនិយោគ និង ធុរកិច្ច និង ការជំរុញ និង ការអភិវឌ្ឍឌីជីថលូបនីយកម្ម ក្នុងប្រព័ន្ធសេដ្ឋកិច្ចទាំងវិស័យសាធារណៈ និងវិស័យឯកជន។

**សសរស្តម្ភទី៣-ការកសាងភាពធន់ (Resilience)÷** តាមរយៈការពង្រឹងការត្រៀមខ្លួន និងការឆ្លើយតបទៅនឹងជំងឺដើម្បីធានាបាននូវចីរភាព និងបរិយាប័ន្ននៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក៏ដូចជាទប់ទល់ទៅនឹងជំងឺ ឬវិបត្តិស្រដៀងគ្នាដែលអាចផ្ទុះឡើងនាពេលអនាគត ដោយផ្ដោតលើការកសាង ធានធានមនុស្ស និងជំរុញផលិតភាព ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ការចាប់យកឱកាស ឌីជីថល ការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម។

**រូបភាពទី៣ ÷** ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣




*ចំណាំ៖ សម្រាប់ខ្លឹមសារលម្អិតសូមមើលក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣*

# ជំពូក ៣

# ថវិកាឆ្នាំ ២០២២

## ៣.១ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២

ឈរលើគោលការណ៍ និងក្នុងគោលបំណងសម្រេចឱ្យបាននូវគោលនយោបាយខាងលើ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ ត្រូវបានកំណត់ដូចខាងក្រោម÷

**តារាងទី២ ÷** សូចនាករក្របខ័ណ្ឌថវិកាឆ្នាំ ២០២០-២០២២

| សូចនាករថវិកា | ២០២០ | | ២០២១ | ២០២២ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (% ផ.ស.ស.) | 24.15 | 21.81 | 18.61 | 20.61 |
| - ចំណូលចរន្ត (% ផ.ស.ស.) | 23.97 | 21.64 | 18.42 | 19.56 |
| ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (% ផ.ស.ស.) | 30.57 | 28.80 | 27.78 | 27.95 |
| - ចំណាយចរន្ត (% ផ.ស.ស.) | 18.17 | 17.25 | 16.28 | 16.79 |
| អតិរេកចរន្ត (% ផ.ស.ស.) | 5.80 | 4.39 | 2.15 | 2.77 |
| ឱនភាពសរុប (% ផ.ស.ស.) | -6.42 | -7.00 | -9.17 | -7.34 |

១. ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ ត្រូវបានគ្រោងចំនួន **២៥ ៥៩៤ ៣៦៦ លានរៀល**, សមមូលនឹងប្រមាណ **៦,៣ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា **២០,៦១%** នៃ ផ.ស.ស. មានកំណើន ១៩,៣% ធៀបនឹងច្បាប់ឆ្នាំ ២០២១ ។ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង **១៩,៥៦%** នៃ ផ.ស.ស. ដែលមានកំណើនចំនួន ១,១៤ ពិន្ទុភាគរយនៃ ផ.ស.ស. ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១ ពោលគឺនឹងសម្រេចបានខ្ពស់ជាង គោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម ០,៣ ពិន្ទុភាគរយ នៃ ផ.ស.ស. ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រគៀរគរចំណូល ឆ្នាំ ២០១៩-២០២៣។

២. <u>**ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ**</u> ត្រូវបានគ្រោងចំនួន **៣៤ ៧០៨ ៦៣០ លានរៀល**, សមមូលនឹងប្រមាណ **៨,៥ ប៊ីលានដុល្លារអាម៉េរិក**, ស្មើនឹង ២៧,៩៥% នៃ ផ.ស.ស. មានកំណើន ៨,៤% ធៀបនឹងច្បាប់ឆ្នាំ ២០២១; ក្នុងនោះ ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងចំនួន **២០ ៨៥០ ៤៤០ លានរៀល**, សមមូលនឹងប្រមាណ **៥,១ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា ១៦,៧៩% នៃ ផ.ស.ស. កើនឡើង ១១,២% ធៀបនឹងច្បាប់ឆ្នាំ ២០២១ ។

៣. <u>**តុល្យភាពរួមនៃថវិកាឆ្នាំ ២០២២**</u> នៅក្នុងក្របខ័ណ្ឌថវិការដ្ឋ ឬ ថវិកាជាតិ, ទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ, រាជរដ្ឋាភិបាលអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ **២,៧៧%** នៃ ផ.ស.ស. នៅឆ្នាំ ២០២២ ធៀបនឹងច្បាប់ឆ្នាំ ២០២១ ដែលមានចំនួន ២,១៥% នៃ ផ.ស.ស.។ ជាលទ្ធផល, ឱនភាពថវិកាជាតិសរុប នឹងមានទំហំស្មើនឹង **-៧,៣៤%** នៃ ផ.ស.ស. គឺថយចុះពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០២១ ដែលស្មើនឹង **-៩,១៧%** នៃ ផ.ស.ស.។ ឱនភាពនេះត្រូវបានបំពេញតុល្យភាពដោយ ÷

(១). **ហិរញ្ញប្បទានក្រៅប្រទេស** ក្នុងទំហំ ៤,៦៨% នៃ ផ.ស.ស.

(២). **មូលនិធិទ្រទ្រង់ថវិកា** ក្នុងទំហំ ១,០២% នៃ ផ.ស.ស.

(៣). **ការបោះផ្សាយលក់មូលបត្ររដ្ឋ** ក្នុងទំហំ ០.៩៨% នៃ ផ.ស.ស. ស្មើនឹង ១ ២១៩ ប៊ីលាន រៀល, សមមូលនឹងប្រមាណ ៣០០ លានដុល្លារអាម៉េរិក; និង

(៤). **ប្រាក់បញ្ញើរាជរដ្ឋាភិបាល** ក្នុងទំហំ ១,៦៤% នៃ ផ.ស.ស. ស្មើនឹង ២ ០៣២ ប៊ីលានរៀល, សមមូលនឹង ៥០០ លានដុល្លារអាម៉េរិក ដែលត្រូវបានគ្រោងយកមកប្រើប្រាស់សម្រាប់អនុវត្តគោលនយោបាយ និង វិធានការរក្សាលំនឹង ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ជាពិសេសសម្រាប់អនុវត្ត "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លង-ប្រក្រតីភាពថ្មី"។

## ៣.២ គម្រោងចំណូល-ចំណាយថវិការដ្ឋ

### ៣.២.១ គម្រោងចំណូលថវិការដ្ឋ

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលសរុបថវិការដ្ឋ ឬ ថវិកាជាតិ ឱ្យស្មើនឹង ៣២ ៦៧៦ ១៣០ លានរៀល ក្នុងនោះចំណូលចរន្តថ្នាក់ជាតិឱ្យស្មើនឹង ២២ ១៥៧ ៣៤៣ លានរៀល (ដែលរួមមានចំណូលសារពើពន្ធ ២០ ២២៧ ០០៥ លានរៀល និង ចំណូលមិនមែន សារពើពន្ធ ១ ៩៣០ ៣៣៨ លានរៀល)។ ដោយឡែក ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៨ ៣៨៧ ០២៣ លានរៀល, ត្រូវជា ៦,៧៥% នៃផ.ស.ស. មានកំណើន ២៨,២% ធៀបនឹងច្បាប់ឆ្នាំ ២០២១ ដែលក្នុងនោះចំណូលមូលធនក្រៅប្រទេសស្មើនឹងប្រមាណ ២០%នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០២២ ប៉ុណ្ណោះ។

**តារាងទី៣ ៖** ចំណូលថវិកាឆ្នាំ ២០២១-២០២២

| ចំណូលថវិកា (ឯកតា៖ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| សរុបចំណូលថវិការដ្ឋ ឬ ថវិកាជាតិ | 27,768,742 | 24.10% | 32,676,130 | 26.32% |
| • ថ្នាក់ជាតិ | 26,250,336 | 22.78% | 30,544,366 | 24.60% |
| • ថ្នាក់ក្រោមជាតិ | 1,518,406 | 1.32% | 2,131,764 | 1.72% |
| ១. ចំណូលចរន្តថវិការដ្ឋ | 21,224,389 | 18.42% | 24,289,107 | 19.56% |
| ក. ចំណូលសារពើពន្ធថវិការដ្ឋ | 18,570,323 | 16.12% | 21,811,132 | 17.57% |
| • ថ្នាក់ជាតិ | 17,520,000 | 15.21% | 20,227,005 | 16.29% |
| • ថ្នាក់ក្រោមជាតិ | 1,050,323 | 0.91% | 1,584,127 | 1.28% |

| ចំណូលថវិកា (ឯកតា÷ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| ១. ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ | 2,654,066 | 2.30% | 2,477,975 | 2.00% |
| • ថ្នាក់ជាតិ | 2,185,983 | 1.90% | 1,930,338 | 1.55% |
| • ថ្នាក់ក្រោមជាតិ | 468,083 | 0.41% | 547,637 | 0.44% |
| ២. ចំណូលមូលធនថវិការដ្ឋ | 6,544,353 | 5.68% | 8,387,023 | 6.75% |
| • ក្នុងប្រទេស | 221,203 | 0.19% | 1,305,259 | 1.05% |
| • ក្រៅប្រទេស | 6,323,150 | 5.49% | 7,081,764 | 5.70% |

**ក្រាហ្វិចទី៤÷** ចំណូលថវិកាឆ្នាំ ២០២២



## ៣.២.២ គម្រោងចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០២២ **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ** ត្រូវបានគ្រោងចំនួន **៣៤ ៧០៨ ៦៣០ លានរៀល** ត្រូវជា ២៧,៩៥% នៃ ផ.ស.ស. មានកំណើន ៨,៤% ធៀបនឹងច្បាប់ឆ្នាំ ២០២១ ដែលក្នុងនោះ (១)-**ចំណាយចរន្តថវិការដ្ឋមានចំនួន ២០ ៨៥០ ៤៤០ លានរៀល** ត្រូវជា ១៦,៧៩% នៃ ផ.ស.ស. កើនឡើង ១១,២% ធៀបនឹងច្បាប់ឆ្នាំ ២០២១ និង (២)-**ចំណាយមូលធនថវិការដ្ឋមានចំនួន ១៣ ៨៥៨ ១៩០ លានរៀល** ត្រូវជា ១១,១៦% នៃ ផ.ស.ស. មានកំណើន ៤,៥% ធៀបនឹងច្បាប់ឆ្នាំ ២០២១។

**តារាងទី៤ ÷** ចំណាយថវិកាឆ្នាំ ២០២១-២០២២

| ចំណាយថវិកា (ឯកតា÷ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| សរុបចំណាយថវិការដ្ឋ ឬ ថវិកាជាតិ | 32,009,742 | 27.78% | 34,708,630 | 27.95% |
| • ថ្នាក់ជាតិ* | 30,491,336 | 26.47% | 32,576,866 | 26.24% |
| • ថ្នាក់ក្រោមជាតិ | 2,578,856 | 2.24% | 3,394,814 | 2.73% |
| ១. ចំណាយចរន្តថវិការដ្ឋ | 18,751,041 | 16.28% | 20,850,440 | 16.79% |
| ១.១. ថ្នាក់ជាតិ | 17,446,841 | 15.14% | 19,111,704 | 15.39% |
| • បន្ទុកបុគ្គលិក | 8,565,575 | 7.43% | 8,653,955 | 6.97% |
| • ក្រៅបន្ទុកបុគ្គលិក | 8,881,267 | 7.71% | 10,457,749 | 8.42% |
| ១.២. ថ្នាក់ក្រោមជាតិ | 2,364,650 | 2.05% | 3,001,786 | 2.42% |
| • បន្ទុកបុគ្គលិក | 761,015 | 0.66% | 779,801 | 0.63% |
| • ក្រៅបន្ទុកបុគ្គលិក | 1,603,635 | 1.39% | 2,221,985 | 1.79% |
| ២. ចំណាយមូលធនថវិការដ្ឋ | 13,258,701 | 11.51% | 13,858,190 | 11.16% |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 6,607,861 | 5.74% | 6,567,049 | 5.29% |
| + ក្នុងនោះចំណាយមូលធនថ្នាក់ក្រោមជាតិ | 214,206 | 0.19% | 393,028 | 0.32% |
| - ការទូទាត់ប្រាក់ខ្ចី | 1,185,190 | 1.03% | 1,477,657 | 1.19% |

| ចំណាយថវិកា (ឯកតា÷ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5,465,650 | 4.74% | 5,813,484 | 4.68% |

*តួលេខនេះរួមបញ្ចូលការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក្រាហ្វិចទី៥ ÷** ចំណាយថវិកាឆ្នាំ ២០២២



# ៣.៣ ថវិកាថ្នាក់ជាតិ

## ៣.៣.១ ចំណូលថវិកាថ្នាក់ជាតិ

គម្រោងចំណូលថវិកាថ្នាក់ជាតិមានសមាសធាតុដូចខាងក្រោម ÷

**តារាងទី៥÷** សូចនាករចំណូលថវិកាឆ្នាំ ២០២០-២០២២

| សូចនាករថវិកា | ២០២០ | | ២០២១ | ២០២២ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| ចំណូលថវិកាថ្នាក់ជាតិសរុប (% ផ.ស.ស.) | ២៧,៨៧ | ២៦,១៣ | ២២,៧៨ | ២៤,៦០ |
| ចំណូលក្នុងប្រទេសថ្នាក់ជាតិ (% ផ.ស.ស.) | ២២,០៩ | ១៩,៨១ | ១៧,៣០ | ១៨,៩០ |
| ចំណូលចរន្តថវិកាថ្នាក់ជាតិ (% ផ.ស.ស.) | ២១,៩១ | ១៩,៦៤ | ១៧,១០ | ១៧,៨៥ |
| ចំណូលមូលធន (% ផ.ស.ស.) | ៥,៩៦ | ៦,៤៩ | ៥,៦៨ | ៦,៧៥ |
| ចំណូលមូលធនក្នុងប្រទេស (% ផ.ស.ស.) | ០,១៨ | ០,១៧ | ០,១៩ | ១,០៥ |
| ចំណូលមូលធនក្រៅប្រទេស (% ផ.ស.ស.) | ៥,៧៨ | ៦,៣២ | ៥,៤៩ | ៥,៧០ |

ថវិកាឆ្នាំ ២០២២ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យស្មើនឹង១៨,៩០%នៃ ផ.ស.ស. គឺស្មើនឹង២៣ ៤៦២ ៦០២លានរៀល ដែលកើនឡើង១៧,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។

ក- **ចំណូលចរន្តថវិកាថ្នាក់ជាតិ** ត្រូវសម្រេចឱ្យបានចំនួន២២ ១៥៧ ៣៤៣លានរៀល ត្រូវជា១៧,៨៥%នៃ ផ.ស.ស. គឺមានកើនឡើង១២,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដែលក្នុងនោះ÷

- **ចំណូលសារពើពន្ធ** ត្រូវសម្រេចឱ្យបានចំនួន២០ ២២៧ ០០៥លានរៀល ត្រូវជា១៦,២៩%នៃ ផ.ស.ស. គឺមានកើនឡើង១៥,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷
  - **ចំណូលគយនិងរដ្ឋាករ** ត្រូវបានគ្រោងចំនួន១០ ៤០០ ០០៥លានរៀល ត្រូវជា៨,៣៨%នៃ ផ.ស.ស. គឺមានការកើនឡើង៩,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១

- **ចំណូលពន្ធដារ** ត្រូវបានគ្រោងចំនួន៩ ៨២៧ ០០០លានរៀល ត្រូវជា ៧,៩១%នៃ ផ.ស.ស. គឺមានការកើនឡើង២២,៥%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងពេលដែលនៅឆ្នាំ ២០២២ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មី ឬបង្កើនអត្រាពន្ធនោះទេ។

- **ចំណូលមិនមែនសារពើពន្ធ** ត្រូវបានគ្រោងចំនួន១ ៩៣០ ៣៣៨លានរៀល ត្រូវជា១,៥៥%នៃ ផ.ស.ស. គឺមានការថយចុះ១១,៧%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷
  - **ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន១ ៧៥៦ ១៨៧លានរៀល ថយចុះ៩,៥%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១
  - **ចំណូលពាក់ព័ន្ធនឹងកាតព្វកិច្ចពីកាស៊ីណូ ឆ្នោត អាជ្ញាប័ណ្ណ** ត្រូវបានគ្រោងចំនួន១៧៤ ១៥២លានរៀល ថយចុះ២៩,២%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។

ខ- **ចំណូលមូលធន** ត្រូវបានគ្រោងចំនួន៨ ៣៨៧ ០២៣លានរៀល ត្រូវជា ៦,៧៥%នៃ ផ.ស.ស. គឺមានកំណើន២៨,២%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដែលក្នុងនោះ÷

- **ចំណូលមូលធនក្នុងប្រទេស** ត្រូវបានកំណត់សម្រេចឱ្យបានចំនួន ១ ៣០៥ ២៥៩លានរៀល ត្រូវជា១,០៥%នៃ ផ.ស.ស. គឺមានកំណើន៤៩០,១%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷
  - **ចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមពីសហគ្រាសសាធារណៈរបស់រដ្ឋ** ត្រូវបានគ្រោងចំនួន៨៥ ៧៥៩លានរៀល ត្រូវជា០,០៧%នៃផ.ស.ស. គឺថយចុះ៦១,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១
  - **ចំណូលដែលបានមកពីការគ្រោងធ្វើការបោះផ្សាយមូលបត្ររដ្ឋជាលើកដំបូង** ត្រូវបានកំណត់ចំនួន១ ២១៩ ៥០០លានរៀល ឬសមមូលនឹងប្រមាណ៣០០លានដុល្លារអាម៉េរិក ត្រូវជា០,៩៨%នៃ ផ.ស.ស.។

- **ចំណូលមូលធនក្រៅប្រទេស** ត្រូវសម្រេចឱ្យបានចំនួន ៧ ០៨១ ៧៦៤ លានរៀល ត្រូវជា៥,៧០% នៃ ផ.ស.ស. គឺមានកំណើន១២,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷
  - **មូលនិធិទ្រទ្រង់ថវិកា** ត្រូវបានគ្រោងចំនួន ១ ២៦៨ ២៨០លានរៀល ត្រូវជា១,០២%នៃ ផ.ស.ស. គឺមានកំណើន៤៧,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១
- **ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់គម្រោងវិនិយោគ** ដែលមានប្រភពពីហិរញ្ញប្បទានឥតសំណងនិងពីការខ្ចីត្រូវបានគ្រោងចំនួន ៥ ៨១៣ ៤៨៤លានរៀល ត្រូវជា៤,៦៨%នៃ ផ.ស.ស. គឺមានការកើនឡើង៦,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។

### ៣.៣.២ ចំណាយថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០២២ មានទិសដៅជាយុទ្ធសាស្ត្រកំណត់**ចំណាយថវិកាថ្នាក់ជាតិ**ឱ្យស្ថិតក្នុងកម្រិតចំនួន ៣២ ៥៧៦ ៨៦៦ លានរៀល ត្រូវជា ២៦,២៤% នៃ ផ.ស.ស. មានកំណើន ៦,៨% ធៀបនឹងច្បាប់ឆ្នាំ ២០២១ ដែលក្នុងនោះ **ចំណាយចរន្តថ្នាក់ជាតិ** មានចំនួន ១៩ ១១១ ៧០៤ លានរៀល ត្រូវជា ១៥,៣៩% នៃ ផ.ស.ស. គឺកើនឡើង៩,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ និង **ចំណាយមូលធនថ្នាក់ជាតិ**មានចំនួន ១៣ ៤៦៥ ១៦២ លានរៀលត្រូវជា ១០,៨៤% នៃ ផ.ស.ស. កើនឡើង៣,២%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។ ចំណាយចរន្តថ្នាក់ជាតិមានសមាសធាតុចំណាយធំៗពីរគឺ ចំណាយលើបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក។

**ក. ចំណាយលើបន្ទុកបុគ្គលិក** រួមមាន÷ បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ លាភការ រង្វាន់ផ្សេងៗ និងប្រាក់វិភាជសង្គមសម្រាប់ថ្នាក់ដឹកនាំនៃស្ថាប័នសាធារណៈ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ មន្ត្រីជាប់កិច្ចសន្យាត្រូវបានគ្រោងចំនួន ៨ ៦៥៣ ៩៥៥ លានរៀល មានសមាមាត្រស្មើនឹង៤៥,៣% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា ៦,៩៧% នៃ ផ.ស.ស. មានកំណើន ១,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។ ចំណាយបន្ទុកបុគ្គលិកនេះ ត្រូវបានគ្រោងដោយរក្សាកម្រិតប្រាក់បៀវត្ស

អប្បបរមា និងប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងកម្លាំងប្រដាប់អាវុធឆ្នាំ ២០២២ ស្មើនឹងកម្រិតឆ្នាំ ២០២១ ដើម្បីរាជរដ្ឋាភិបាលនៅមានលទ្ធភាពសន្សំថវិកាសម្រាប់បន្តការងារអន្តរាគមន៍ផ្នែកសុខាភិបាល និងសង្គម ពិសេសគឺការបង្កើនកញ្ចប់ថវិកាជួយជនក្រីក្រ (ក្រ១ និង ក្រ២) និងជនងាយរងគ្រោះ ឱ្យបានដល់ ៩ ខែ ជាបន្តទៀតនៅក្នុងឆ្នាំ ២០២២។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តធានាបាននូវការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការឱ្យបានទាន់ពេលវេលា គឺ២ដង ក្នុង១ខែ ដោយមិនមានការកាត់ប្រាក់បៀវត្សមន្ត្រីរាជការគ្រប់ប្រភេទ ហើយកម្រិតប្រាក់បៀវត្សអប្បបរមាឆ្នាំ ២០២២ ត្រូវបានរក្សាដូចខាងក្រោម÷

- **បៀវត្សមន្ត្រីរាជការស៊ីវិល** រក្សាស្មើនឹងប្រមាណ ១ ១៧២ ៥០០ រៀល;
- **បៀវត្សគ្រូបង្រៀន និង គ្រូពេទ្យ** រក្សាស្មើនឹងប្រមាណ ១ ២៧២ ៥០០ រៀល;
- **បៀវត្សនគរបាល(ពលបាលត្រី)** រក្សាស្មើនឹងប្រមាណ ១ ២៥៦ ៩៧៧ រៀល (គិតបញ្ចូលរបបអង្គរ);
- **បៀវត្សយោធិន (ពលទោ)** រក្សាស្មើនឹងប្រមាណ ១ ១២៣ ៥០០ រៀល (មិនគិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលរបបអង្គរត្រូវជាប្រមាណ ១ ១៨១ ៩៧៧ រៀល។

ចំពោះប្រាក់បំណាច់ប្រចាំខែរបស់មន្ត្រីជាប់កិច្ចសន្យា ក៏ត្រូវបានរក្សាស្មើនឹងកម្រិតឆ្នាំ ២០២១ផងដែរគឺចំនួន ៦៧០ ០០០រៀល។ ដោយឡែកប្រាក់សោធននិវត្តន៍ ត្រូវបានគ្រោងថវិកាចំនួន៣០ប៊ីលានរៀល សម្រាប់ ការកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកចូលនិវត្តន៍ចាស់ និងអ្នកចូលនិវត្តន៍ថ្មី ជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធផងដែរ។

ការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការរក្សាកម្រិតបៀវត្សអប្បបរមា និងបៀវត្សមន្ត្រីរាជការឆ្នាំ ២០២២ ស្មើនឹងកម្រិតឆ្នាំ ២០២១ និងការមិនអនុញ្ញាតឱ្យជ្រើសរើសក្របខ័ណ្ឌថ្មី ជំនួសអ្នកចូលនិវត្តន៍លើកលែងក្រសួងស្ថាប័ន ដែលមានគោលការណ៍ដោយឡែកពីរាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពសន្សំថវិកាបានចំនួនប្រមាណ **១០០លានដុល្លារអាម៉េរិក** សម្រាប់ត្រៀមបន្តអន្តរាគមន៍ផ្នែកសុខាភិបាល និងសង្គម ព្រមទាំងអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច ដើម្បីបន្តទប់ទល់នឹងផលប៉ះពាល់នៃការអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩។ ទោះបីជាយ៉ាងនេះក្តី

រាជរដ្ឋាភិបាលអនុញ្ញាតឱ្យរៀបចំបៀវត្សតាមឋានន្តរស័ក្តិ និងថ្នាក់ សម្រាប់ឆ្នាំ ២០២២ តែមិនអនុញ្ញាតឱ្យគិតត្រឡប់ក្រោយតាំងពីឆ្នាំ ២០២១ នោះទេ។

លើសពីនេះ សម្រាប់ឆ្នាំ ២០២២ នេះដែរ **រាជរដ្ឋាភិបាលបានគ្រោងថវិកាចំនួន៤០ប៊ីលានរៀល ដោយឡែកផ្សេងទៀត សម្រាប់ផ្តល់លទ្ធភាពដល់ក្រសួង ស្ថាប័នអាចជ្រើសរើសមន្ត្រីមានសមត្ថភាពនិងជំនាញខ្ពស់ចូលបម្រើការងាររដ្ឋ។** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងសហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំក្របខ័ណ្ឌ និងគោលការណ៍ និងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ២០២២។

ដូចឆ្នាំមុនដែរ **រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន៥០ប៊ីលានរៀល សម្រាប់មូលនិធិថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងបានបន្តគ្រោងថវិកាចំនួន៦ប៊ីលានរៀល សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ដើម្បីលើកកម្ពស់សុខភាពមន្ត្រីរាជការស៊ីវិល** នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។

**ខ. ចំណាយមិនមែនបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន ១០ ៤៥៧ ៧៤៩ លានរៀល, មានសមាមាត្រស្មើនឹង ៥៤,៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៨,៤២% នៃ ផ.ស.ស. មានកំណើន ១៧,៨% ធៀបនឹងច្បាប់ឆ្នាំ ២០២១។ ជារួម គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ជាទូទៅគោរពបាននូវពិតានចំណាយគោលដែលរាជរដ្ឋាភិបាលបានកំណត់ផ្តល់ជូនសម្រាប់ចំណាយមិនមែនបន្ទុកបុគ្គលិកក្នុងកម្រិតថវិកាវិចារណកម្មចំណាយឆ្នាំ ២០២១ ក្នុងក្របខ័ណ្ឌនៃការធ្លាក់ចុះចំណូល។ ប៉ុន្តែកំណើនចំណាយមិនមែនបន្ទុកបុគ្គលិកដែលបានគ្រោង គឺសម្រាប់ការអនុវត្តអាទិភាពចម្បងសំខាន់ៗ រួមមាន÷ ការបន្តអន្តរាគមន៍ប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩, ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់, ការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងអាទិភាពមួយចំនួនទៀត។ កញ្ចប់ថវិកានេះ ត្រូវបានវិភាជទៅតាមវិស័យចំណាយដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ដូចខាងក្រោម÷

## ចំណាយវិស័យរដ្ឋបាលទូទៅ

- គាំទ្រដល់ការរៀបចំដំណើរការបោះឆ្នោតឃុំ- សង្កាត់ឆ្នាំ ២០២២,
- គាំទ្រដល់ការរៀបចំធ្វើជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាននឆ្នាំ ២០២២ ក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ,
- បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ,
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ,
- បន្តគាំទ្រកំណែទម្រង់វិស័យដីធ្លី,
- បន្តគាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥,
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ,
- បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការទូត ។

## ចំណាយវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- បន្តគាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ,
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ,
- បន្តគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ,
- បន្តគាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ,
- បន្តគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ,
- បន្តគាំទ្រការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព,
- បន្តគាំទ្រដល់ប្រព័ន្ធត្រួតពិនិត្យសន្តិសុខតាមច្រកព្រំដែន និងការផលិតលិខិតឆ្លងដែន,
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ,
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន,
- បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

## ចំណាយវិស័យសង្គមកិច្ច

- បន្តគាំទ្រការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩,
- បន្តគាំទ្រដល់ការលើកកម្ពស់គុណភាព និងការទទួលបានសេវាសុខាភិបាល,
- បន្តគាំទ្រដល់ការពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ,
- បន្តគាំទ្រដល់ការលើកកម្ពស់វិស័យកីឡាជាតិ,
- បន្តគាំទ្រដល់ការអភិវឌ្ឍន៍ជំនាញ និងវិស័យការងារ,
- បន្តគាំទ្រដល់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ,
- បន្តឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន,
- បន្តឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា,
- បន្តផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រនិងចាស់ជរានៅតាមសហគមន៍,
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ,
- បន្តគាំទ្រដល់ការការពារ និងអភិរក្សធនធានធម្មជាតិ,
- បន្តគាំទ្រដល់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ,
- បន្តគាំទ្រដល់សុខដុមនីយកម្មសាសនា។

## ចំណាយវិស័យសេដ្ឋកិច្ច

- បន្តគាំទ្រដល់ការលើកកម្ពស់បច្ចេកទេសកសិកម្ម និង សុវត្ថិភាពចំណីអាហារ,
- បន្តគាំទ្រដល់ការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល,
- បន្តគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ,
- បន្តគាំទ្រដល់ការអភិវឌ្ឍន៍ទឹកស្អាត និងអនាម័យជនបទ,
- បន្តគាំទ្រដល់ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ,
- ជំរុញការអភិវឌ្ឍន៍ផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍,
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា,
- បន្តគាំទ្រដល់ការជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត,
- បន្តគាំទ្រដល់ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ,

- បន្តគាំទ្រដល់ការអភិវឌ្ឍន៍ប្រព័ន្ធរដ្ឋបាលអេឡិកត្រូនិក,
- បន្តគាំទ្រដល់ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម,
- អភិវឌ្ឍន៍ប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

លើសពីនេះ សម្រាប់ឆ្នាំ ២០២២ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកា ឆ្លើយតប នឹងសកម្មភាពគាំពារសង្គមដែលរួមមានជាអាទិ៍ដូចជា÷

- **ការបន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ÷** បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប. ស. ស.) ទទួលបានរបបថែទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ;
- **ការបន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត÷** បានគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាលសម្រាប់បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅក្រោយពេលសម្រាលកូន និងសម្រាកលំហែមាតុភាព;
- **ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា÷** បន្តផ្តល់ថវិកាសម្រាប់បង្កើន "មូលនិធិគន្ធបុប្ផាកម្ពុជា", បន្ថែមលើថវិកាដែលត្រូវផ្តល់ផ្ទាល់ទៅមន្ទីរពេទ្យគន្ធបុប្ផាសម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០២២, ដើម្បីធានានិរន្តរភាព គុណភាព និងប្រសិទ្ធភាព របស់មន្ទីរពេទ្យផង និងធានាការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រផង;
- **កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូច÷** បានគ្រោងថវិកាសម្រាប់ឧបត្ថម្ភពេលពិនិត្យផ្ទៃពោះ ចំនួន ៤ លើក, ១ លើក ៤ ម៉ឺនរៀល, ពេលសម្រាលកូននៅមណ្ឌលសុខភាព ឬពេទ្យរដ្ឋ ជូន ២០ម៉ឺនរៀល, ឧបត្ថម្ភ ១០ លើកទៀត ១លើក ៤ ម៉ឺនរៀល ពេលទៅទទួលថ្នាំបង្ការរហូតដល់កុមារអាយុ ២ ឆ្នាំ។

**គ. ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន ១៣ ៤៦៥ ១៦២ លានរៀល មានសមាមាត្រស្មើនឹង៤១,៣% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា ១០,៨៤% នៃ ផ. ស. ស. មានកំណើន ៣,២២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (២០២២-២០២៤)

ជាពិសេសការអនុវត្ត "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"។ គម្រោងចំណាយមូលធននេះ ត្រូវបានបែងចែកជាសមាសធាតុធំៗពីរដូចខាងក្រោម÷

**១- គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស** ត្រូវបានគ្រោងចំនួន ៦ ១៧៤ ០២១ លានរៀល ត្រូវជា ៤,៩៧% នៃ ផ.ស.ស. ថយចុះ ៣,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។ អាទិភាពនៃចំណាយគម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសផ្តោតអាទិភាពទៅលើ÷

- ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន លូ ព្រមទាំងការជួសជុលឡើងវិញនូវ ហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធលូ អូរ ប្រឡាយរំដោះទឹកភ្លៀង និងប្រព័ន្ធបង្ហូរទឹកកខ្វក់,
- ការកសាង និងជួសជុលផ្លូវចំនួន ៣៨ ខ្សែ ក្នុងទីរួមខេត្តសៀមរាប,
- ការបន្តស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ,
- ការជំរុញផលិតកម្មស្បៀង និងការលើកកម្ពស់ផលិតភាពកសិកម្ម,
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួនផ្សេងទៀត ។

**២- គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានគ្រោងចំនួន៩ ៨១៣ ៤៨៤លានរៀល ត្រូវជា៤,៦៨%នៃ ផ.ស.ស. កើនឡើង ៦,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ហើយស្មើនឹងប្រមាណ១៦,៧% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០២២។ គម្រោងចំណាយនេះ គឺជាតួលេខប៉ាន់ស្មាននៃការបើកផ្តល់សាច់ប្រាក់ ទាំងឥណទានសម្បទាន និងទាំងហិរញ្ញប្បទានឥតសំណង ពីដៃគូអភិវឌ្ឍន៍សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈកំពុងដំណើរការនិងគម្រោងថ្មី ដែលបានចុះហត្ថលេខាក្នុងឆ្នាំ ២០២១។

ទន្ទឹមនេះ រាជរដ្ឋាភិបាល ក៏បានគ្រោងថវិកាសម្រាប់ការបន្តត្រៀម**អន្តរាគមន៍ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩** មានជាអាទិ៍ ដូចខាងក្រោម÷

- កម្មវិធីឧបត្ថម្ភគ្រួសារក្រីក្រ (ក្រ១ និងក្រ២) និងជនងាយរងគ្រោះ ត្រូវបានគ្រោងទឹកប្រាក់ចំនួន ១ ១៣៨ ប៊ីលានរៀល សមមូលនឹងប្រមាណ ២៨០ លានដុល្លារអាម៉េរិក,
- កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ ត្រូវបានគ្រោងទឹកប្រាក់ចំនួន ២៣៩ ប៊ីលានរៀល សមមូលនឹងប្រមាណ ៥៩ លានដុល្លារអាម៉េរិក,
- គម្រោងសាច់ប្រាក់ពលកម្ម (Cash for Works) ត្រូវបានគ្រោងទឹកប្រាក់ចំនួន ៤០៦ ប៊ីលានរៀល សមមូលនឹងប្រមាណ ១០០ លានដុល្លារអាម៉េរិក សម្រាប់ស្រូបយកកម្លាំងពលកម្មដែលបាត់បង់ការងារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅជនបទ មានដូចជា ប្រឡាយជើងក្អែប ស្រះទឹក អណ្តូង និងបង្គន់អនាម័យនៅតាមសាលារៀនជាដើម,
- ហិរញ្ញប្បទានសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ត្រូវបានគម្រោងទឹកប្រាក់ចំនួន ១ ០១៦ ប៊ីលានរៀល សមមូលនឹងប្រមាណ ២៥០ លានដុល្លារអាម៉េរិក,
- គម្រោងប្រព័ន្ធបច្ចេកវិទ្យា និងរចនាសម្ព័ន្ធឌីជីថល ត្រូវបានគ្រោងទឹកប្រាក់ចំនួនប្រមាណ ១០១ ប៊ីលានរៀល សមមូលនឹងប្រមាណ ២៥ លានដុល្លារអាម៉េរិក ។

ជាលទ្ធផលរួម ថវិកាថ្នាក់ជាតិត្រូវបានបែងចែកទៅតាមវិស័យទាំង ៤ ដូចខាងក្រោម៖

**តារាងទី៦៖** ចំណាយថវិកាសរុបតាមវិស័យឆ្នាំ ២០២១-២០២២

| ចំណាយថវិកាតាមវិស័យ (ឯកតា៖ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| ១. វិស័យរដ្ឋបាលទូទៅ | 1,972,197 | 1.71% | 2,088,946 | 1.68% |
| ក. ចំណាយចរន្ត | 1,815,921 | 1.58% | 1,916,131 | 1.54% |
| -បន្ទុកបុគ្គលិក | 692,810 | 0.60% | 694,130 | 0.56% |
| -ក្រៅបន្ទុកបុគ្គលិក | 1,123,111 | 0.97% | 1,222,001 | 0.98% |
| ខ. ចំណាយមូលធន | 156,276 | 0.14% | 172,815 | 0.14% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 16,500 | 0.01% | 0 | 0.00% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 139,776 | 0.12% | 172,815 | 0.14% |
| ២. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | 4,769,559 | 4.14% | 4,795,111 | 3.86% |
| ក. ចំណាយចរន្ត | 4,715,869 | 4.09% | 4,675,287 | 3.77% |
| -បន្ទុកបុគ្គលិក | 3,832,150 | 3.33% | 3,822,770 | 3.08% |
| -ក្រៅបន្ទុកបុគ្គលិក | 883,719 | 0.77% | 852,517 | 0.69% |
| ខ. ចំណាយមូលធន | 53,690 | 0.05% | 119,824 | 0.10% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 20,000 | 0.02% | 22,600 | 0.02% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 33,690 | 0.03% | 97,224 | 0.08% |
| ៣. វិស័យសង្គមកិច្ច | 7,824,906 | 6.79% | 8,449,790 | 6.81% |
| ក. ចំណាយចរន្ត | 6,872,756 | 5.97% | 7,332,061 | 5.91% |
| -បន្ទុកបុគ្គលិក | 3,523,530 | 3.06% | 3,610,626 | 2.91% |

| ចំណាយថវិកាតាមវិស័យ (ឯកតា÷ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| -ក្រៅបន្ទុកបុគ្គលិក | 3,349,227 | 2.91% | 3,721,435 | 3.00% |
| ខ. ចំណាយមូលធន | 952,150 | 0.83% | 1,117,729 | 0.90% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 90,000 | 0.08% | 110,000 | 0.09% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 862,150 | 0.75% | 1,007,729 | 0.81% |
| ៤. វិស័យសេដ្ឋកិច្ច | 6,425,789 | 5.58% | 6,531,922 | 5.26% |
| ក. ចំណាយចរន្ត | 1,459,755 | 1.27% | 1,457,206 | 1.17% |
| -បន្ទុកបុគ្គលិក | 517,085 | 0.45% | 526,429 | 0.42% |
| -ក្រៅបន្ទុកបុគ្គលិក | 942,670 | 0.82% | 930,777 | 0.75% |
| ខ. ចំណាយមូលធន | 4,966,034 | 4.31% | 5,074,716 | 4.09% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 536,000 | 0.47% | 539,000 | 0.43% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4,430,034 | 3.85% | 4,535,716 | 3.65% |

## ក្រាហ្វិកទី៦÷ ចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័នឆ្នាំ ២០២២




1 កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
2 ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
3 គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
4 ពាណិជ្ជកម្ម
5 រដ្ឋសភា
6 យុត្តិធម៌
7 វប្បធម៌និងវិចិត្រសិល្បៈ
8 ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
9 ប្រៃសណីយ៍និងទូរគមនាគមន៍
10 រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
11 បរិស្ថាន
12 ទេសចរណ៍
13 ផែនការ
14 ព័ត៌មាន
15 ព្រះបរមរាជវាំង
16 ព្រឹទ្ធសភា
17 ធម្មការ និងសាសនា
18 មុខងារសាធារណៈ
19 កិច្ចការនារី
20 រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
21 ស្ថាប័នប្រឆាំងអំពើពុករលួយ
22 ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
23 ក្រុមប្រឹក្សាធម្មនុញ្ញ
24 អាជ្ញាធរសវនកម្មជាតិ
25 ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ចំណាំ÷ លេខរៀងពី 1 ដល់ 25 សម្រាប់សំគាល់ឈ្មោះក្រសួង ស្ថាប័ននៅក្នុងក្រាហ្វិកខាងលើ

## ៣.៤ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

គម្រោងចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត ក្រុង ស្រុក និង ឃុំ-សង្កាត់) ត្រូវបានរៀបចំឡើងដោយឈរលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងរាល់ក្របខណ្ឌគតិយុត្តដែលមានជាធរមាន។

- **ចំណូលចរន្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក** ត្រូវបានគ្រោងចំនួន២ ១៣១ ៧៦៤លានរៀល មានសមាមាត្រស្មើនឹង៨,៩%នៃចំណូលចរន្តថវិការដ្ឋ ត្រូវជា១,៧២%នៃ ផ.ស.ស. មានការកើនឡើង ៤០,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះរួមមាន÷
  - ចំណូលសារពើពន្ធ ត្រូវបានគ្រោងចំនួន១ ៥៨៤ ១២៧លានរៀល ត្រូវជា ១,២៨%នៃ ផ.ស.ស. កើនឡើង៥០,៨%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១
  - ចំណូលមិនមែនសារពើពន្ធ ត្រូវបានគ្រោងចំនួន ៥៤៧ ៦៣៧លានរៀល ត្រូវជា ០,៤៤%នៃ ផ.ស.ស. មានកំណើន១៧,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។

- **ចំណាយសរុបថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ត្រូវបានគ្រោងចំនួន ៣ ៣៩៤ ៨១៤លានរៀល មានសមាមាត្រស្មើនឹង ៩,៨%នៃចំណាយថវិការដ្ឋសរុប ត្រូវជា២,៧៣%នៃ ផ.ស.ស. កើនឡើង ៣១,៦%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷

**ក. ចំណាយចរន្ត:** ត្រូវបានគ្រោងចំនួន ៣ ០០១ ៧៨៦លានរៀល មានសមាមាត្រស្មើនឹង ១៤,៤%នៃចំណាយចរន្តថវិការដ្ឋសរុប ត្រូវជា ២,៤២%នៃ ផ.ស.ស. កើនឡើង ២៦,៩%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។ ក្នុងទំហំចំណាយចរន្តនេះ ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ និង ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងឆ្នាំ ២០២២ ត្រូវបានរក្សាស្មើនឹងកម្រិតឆ្នាំ ២០២១។

ដូចនេះ ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ក៏ដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីភូមិ ត្រូវបានផ្តល់ជូនដូចខាងក្រោម៖

- **ក្រុមប្រឹក្សារាជធានី ខេត្ត៖**
  - ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សារាជធានី-ខេត្ត នឹងទទួលបានចំនួន ១ ៤៤០ ០០០រៀល
  - ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត នឹងទទួលបានចំនួន ១ ១៣៥ ០០០រៀល។
- **ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ៖**
  - ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ នឹងទទួលបានចំនួន ១ ១៥៥ ០០០រៀល
  - ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ នឹងទទួលបានចំនួន ៩១០ ០០០រៀល។
- **ក្រុមប្រឹក្សាឃុំ សង្កាត់៖**
  - ប្រាក់បំណាច់មេឃុំចៅសង្កាត់ នឹងទទួលបានចំនួន១ ១១០ ០០០រៀល
  - ប្រាក់បំណាច់ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ នឹងទទួលបានចំនួន ៨៧០ ០០០រៀល
  - ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ នឹងទទួលបានចំនួន ៧៦០ ០០០រៀល
  - ប្រាក់បំណាច់មេភូមិ នឹងទទួលបានចំនួន៤៣០ ០០០រៀល
  - ប្រាក់បំណាច់អនុប្រធានភូមិ នឹងទទួលបានចំនួន៣១០ ០០០រៀល និង
  - ប្រាក់បំណាច់សមាជិកភូមិ នឹងទទួលបានចំនួន២៨០ ០០០រៀល។

**ខ.ចំណាយមូលធន:** ត្រូវបានគ្រោងចំនួន៣៩៣ ០២៨លានរៀល មានសមាមាត្រ ៦,០%នៃចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវជា០,៣២%នៃ ផ.ស.ស.។

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក និង ឃុំ-សង្កាត់ខាងលើ បានធ្វើឱ្យមានឱនភាពថវិកាចំនួន ១ ២៦៣ ០៥០ លានរៀល ត្រូវជា ១,០២% នៃ ផ.ស.ស. ដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ដែលការឧបត្ថម្ភនេះកើនឡើង ១៩,១% ធៀបនឹងច្បាប់ឆ្នាំ ២០២១ ក្នុងនោះ÷

**(១)- ឧបត្ថម្ភរាជធានី-ខេត្ត(សម្រាប់រដ្ឋបាលខ័ណ្ឌ)** ចំនួន ១៣ ៣០៤ លានរៀល ដើម្បីអនុវត្តការផ្ទេរមុខងាររបស់មន្ទីរជំនាញ;

**(២)- ឧបត្ថម្ភក្រុង-ស្រុក** ចំនួន ៤០២ ៣៨៩ លានរៀល, មានកំណើន ១៩,០% ធៀបនឹងច្បាប់ឆ្នាំ ២០២១;

**(៣)- ឧបត្ថម្ភឃុំ-សង្កាត់** ចំនួន ៦៥០ ២៩៧ លានរៀល, មានកំណើន ២០,៣% ធៀបនឹងច្បាប់ឆ្នាំ ២០២១;

**(៤)- មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់** ចំនួន ១៩៧ ០៦០ លានរៀល, ស្មើនឹង ០,១៦% នៃ ផ.ស.ស. មានកំណើន ១៦,៦% ធៀបនឹងច្បាប់ឆ្នាំ ២០២១, ដែលជាការផ្ទេរធនធានបន្ថែមជូនរដ្ឋបាលឃុំ-សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ចាប់ពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០២៣។ ការឧបត្ថម្ភធនបន្ថែមនេះ នឹងធ្វើឱ្យរដ្ឋបាលឃុំ-សង្កាត់នីមួយៗ ទទួលបានជាមធ្យមប្រមាណ ២៤២ លានរៀល ឬសមមូលនឹង ៦០ ០០០ ដុល្លារអាមេរិក ជាមធ្យមក្នុង ១ ឆ្នាំ។

**តារាងទី៧÷** ថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២១-២០២២

| ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ឯកតា÷ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ | 1,518,406 | 1.32% | 2,131,764 | 1.72% |
| · ចំណូលសារពើពន្ធ | 1,050,323 | 0.91% | 1,584,127 | 1.28% |
| · ចំណូលមិនមែនសារពើពន្ធ | 468,083 | 0.41% | 547,637 | 0.44% |
| សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ | 2,578,856 | 2.24% | 3,394,814 | 2.73% |
| · ចំណាយចរន្ត | 2,364,650 | 2.05% | 3,001,786 | 2.42% |
| · ចំណាយមូលធន | 214,206 | 0.19% | 393,028 | 0.32% |

| ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ឯកតា÷ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| ឱនភាពថវិកា | -1,060,450 | -0.92% | -1,263,050 | -1.02% |
| ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ | 1,060,450 | 0.92% | 1,263,050 | 1.02% |
| • រាជធានី-ខេត្ត (សម្រាប់រដ្ឋបាលខ័ណ្ឌ) | 12,807 | 0.01% | 13,304 | 0.01% |
| • ក្រុង-ស្រុក | 338,095 | 0.29% | 402,389 | 0.32% |
| • ឃុំ-សង្កាត់ | 540,608 | 0.47% | 650,297 | 0.52% |
| • មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ | 168,940 | 0.15% | 197,060 | 0.16% |

## ៣.៥ ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២២ និងស្ថានភាពបំណុល

ក្នុងការគ្រប់គ្រងបំណុលសាធារណៈ, រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន ៥ ដូចខាងក្រោម÷

(១)- ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន;

(២)- ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខ័ណ្ឌអនុគ្រោះខ្ពស់;

(៣)- ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាព សេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម;

(៤)- ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាពខ្ពស់បំផុត;

(៥)- ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍន៍ជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។

ផ្អែកតាម**ការកំណត់ពិតាននៃការខ្ចីនៅក្នុងច្បាប់ថវិកាឆ្នាំ ២០២២** រាជរដ្ឋាភិបាល បានកំណត់ទំហំនៃការខ្ចីប្រាក់ពីក្នុងប្រទេស និងពីដៃគូអភិវឌ្ឍន៍ ដូចខាងក្រោម÷

**(ក)- គ្រោងធ្វើការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូង ក្នុងកម្រិត ១ ២១៩ ៥០០លានរៀល ឬសមមូលស្មើនឹងប្រមាណ៣០០លានដុល្លារអាម៉េរិក** ដើម្បីធ្វើហិរញ្ញប្បទានគាំទ្រគម្រោងវិនិយោគសំដៅលើកស្ទួយកំណើន និងផលិតភាពសេដ្ឋកិច្ច រួមមាន÷ **ការអនុវត្តយុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី** ដែលត្រូវបានកំណត់រួចហើយ ចំនួន ២៥០ លានដុល្លារអាម៉េរិក និងគម្រោងដែលនឹងកំណត់តាមក្រោយទៀតចំនួន ២៥ លានដុល្លារអាម៉េរិក ព្រមទាំងគម្រោងប្រព័ន្ធបច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលចំនួន ២៥ លានដុល្លារអាម៉េរិក។ គួរបញ្ជាក់ដែរថាការបោះផ្សាយលក់មូលបត្ររដ្ឋនេះ នឹងចូលរួមអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈតួនាទីរបស់មូលបត្ររដ្ឋជាឧបករណ៍អនុវត្តគោលនយោបាយរូបិយវត្ថុ និងជាមូលដ្ឋានប្រៀបធៀប និងកំណត់ថ្លៃឧបករណ៍ហិរញ្ញវត្ថុក្នុងទីផ្សារ ព្រមទាំងជំរុញការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានក្នុងស្រុក។ ដូចនេះ ការបោះផ្សាយលក់មូលបត្ររដ្ឋខាងលើ គឺជាការគិតគូរស្របតាមរបត់ថ្មីនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា ដើម្បីអាចឈានទៅកសាងប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ សម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋទាំងមូលដើម្បីបំពេញបន្ថែមលើភាពមានកម្រិតនៃប្រភពធនធានរបស់រដ្ឋបច្ចុប្បន្ន ខណៈដែលលទ្ធភាពក្នុងការទទួលបានឥណទានសម្បទានខ្ពស់មានការថមថយ ដោយសារការឡើងឋានៈមកជាប្រទេសចំណូលមធ្យមកម្រិតទាបរបស់កម្ពុជា។

**(ខ)- កំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍ ក្នុងកម្រិត១៦០០លានSDR** គឺកើនឡើង១០០លាន SDR ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដោយឈរលើមូលដ្ឋាននៃការគិតគូរ និងផ្អែកទៅលើទិដ្ឋភាពសំខាន់ៗមួយចំនួនដែលរួមមាន÷

១- ទំហំនៃតម្រូវការវិនិយោគសាធារណៈមានការកើនឡើងជាគំហុក ដើម្បីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញឆ្លើយតបនឹងបរិការណ៍នៃផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩,

២- គម្រោងអភិវឌ្ឍន៍ដែលនឹងចុះកិច្ចព្រមព្រៀងឥណទានសម្បទានក្នុងឆ្នាំ ២០២១ ជាគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព (ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបង្កើនផលិតភាពសេដ្ឋកិច្ច និងផលិតភាពផលិតកម្ម) ហើយដែលចេះតែរំកិលពីឆ្នាំមុនៗមក តែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង,

៣- ឥណទានមានកម្រិតសម្បទានខ្ពស់,

៤- ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យមនៅតែមាន “ចីរភាព” និង “ហានិភ័យកម្រិតទាប” និង

៥- ការបន្តបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង។

ជារួម ការកំណត់ពិតានក្នុងការខ្ចីថ្មីសម្រាប់ឆ្នាំ ២០២២ ក្នុងកម្រិត **១ ៦០០ លាន SDR** គឺដើម្បីឱ្យរាជរដ្ឋាភិបាលអាចចុះហត្ថលេខាខ្ចីប្រាក់ពីគេសម្រាប់ហិរញ្ញប្បទានកម្មវិធី/គម្រោងវិនិយោគសាធារណៈចំនួន៣៥ ដែលរួមមាន÷ សាធារណរដ្ឋប្រជាមានិតចិនចំនួន ៦គម្រោង, ព្រះរាជាណាចក្រថៃចំនួន ១គម្រោង, ប្រទេសជប៉ុនចំនួន ៣គម្រោង, សាធារណរដ្ឋកូរ៉េចំនួន ៥គម្រោង, សាធារណរដ្ឋបារាំងចំនួន ៥គម្រោង, ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ចំនួន ១គម្រោង, ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ៩គម្រោង, ធនាគារពិភពលោកចំនួន ៣គម្រោង, ធនាគារវិនិយោគអឺរ៉ុបចំនួន ១គម្រោង, ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ីចំនួន ១គម្រោង, និង ដោយបែងចែកតាមវិស័យ ដូចខាងក្រោម÷

## វិស័យថាមពលចំនួន ៩ គម្រោងគឺ÷

គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ជំហានទី១, គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ជំហានទី២, គម្រោងពង្រីកខ្សែបញ្ជូនអគ្គិសនីជនបទ ជំហានទី៨, គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញ ជំហានទី២, គម្រោងពង្រឹងសមត្ថភាពប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី, គម្រោងសាងសង់ខ្សែបញ្ជូន ១១៥ គីឡូវ៉ុល បារាយណ៍-ស្ទឹងត្រង់, គម្រោងប្រសិទ្ធភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ ជំហានទី២, និងកម្មវិធីអភិវឌ្ឍន៍ប្រសិទ្ធភាពវិស័យថាមពល;

## វិស័យធារាសាស្ត្រចំនួន ៥ គម្រោងគឺ ៖

គម្រោងអភិវឌ្ឍន៍អាងទឹកដងកាំបិត ខេត្តកំពង់ធំ, គម្រោងអភិវឌ្ឍន៍ទំនប់ដូនទ្រីនៅខេត្តបាត់ដំបង (ហិរញ្ញប្បទានបន្ថែម), គម្រោងស្តារឡើងវិញស្ទឹងស្វាយ-ចេក, កម្មវិធីគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរវិស័យកសិកម្ម ជំហានទី២, និងគម្រោងជួសជុល និងស្តារផលប៉ះពាល់ពីទឹកជំនន់ឆ្នាំ ២០២០;

## វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តចំនួន ៧ គម្រោងគឺ៖

គម្រោងសាងសង់ស្ពានទន្លេមេគង្គ និងផ្លូវតភ្ជាប់ ខេត្តក្រចេះ, គម្រោងពង្រីកកំណាត់ផ្លូវជាតិលេខ៧ (ស្គន់-កំពង់ចាម), គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ផ្លូវជាតិលេខ៥ ជំហានទី២, គម្រោងធ្វើឱ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ ពីថ្លាម្អម ខេត្តពោធិ៍សាត់-ក្រុងបាត់ដំបង និងពីក្រុងសិរីសោភ័ណ (កញ្ចប់ឥណទាន ដំណាក់កាលទី៣), គម្រោងកែលម្អបណ្តាញតភ្ជាប់ជនបទដោយចីរភាព, គម្រោងសាងសង់ស្ពានមិត្តភាពកម្ពុជា-កូរ៉េ, និងគម្រោងលើកកម្ពស់សមត្ថភាពបន្សាំនៅជនបទ;

## វិស័យសុខាភិបាលចំនួន ៣ គម្រោងគឺ៖

គម្រោងធ្វើឱ្យប្រសើរឡើងមន្ទីរពេទ្យបង្អែកខេត្ត, គម្រោងពង្រឹងវិស័យសុខាភិបាលក្នុងតំបន់សេដ្ឋកិច្ចពិសេសក្នុងមហាអនុតំបន់មេគង្គ, និង គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល ជំហានទី២;

## វិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ២ គម្រោងគឺ៖

គម្រោងបណ្តុះបណ្តាលជំនាញសម្រាប់តម្រូវការសេដ្ឋកិច្ចពេលអនាគត, និងគម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅមធ្យមសិក្សាទុតិយភូមិ;

## វិស័យកសិកម្មចំនួន ៣ គម្រោងគឺ៖

កម្មវិធីអភិវឌ្ឍន៍កសិកម្មតំបន់ពឹងលើទឹកភ្លៀងសម្រាប់ប្រទេស កម្ពុជា, គម្រោងនេសាទនៅតាមតំបន់ឆ្នេរប្រកបដោយនិរន្តរភាព, និង គម្រោងផលិតកម្មសត្វឆ្លងដែននិងការជំរុញខ្សែច្រវ៉ាក់ផលិតកម្មមហាអនុតំបន់មេគង្គ;

## វិស័យអាទិភាពផ្សេងទៀតចំនួន ៦ គម្រោងគឺ៖

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធចម្រោះទឹកកខ្វក់ ក្រុងតាខ្មៅ (ឥណទានបន្ថែម), កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុកម្មវិធីទី២, គម្រោងគាំទ្រការសិក្សាសមិទ្ធិលទ្ធភាពនិងការអនុវត្តគម្រោង, កម្មវិធីជំរុញពាណិជ្ជកម្ម និងការប្រកួតប្រជែង អនុកម្មវិធីទី១, គម្រោងគ្រប់គ្រងធនធានធម្មជាតិ, គម្រោងសេដ្ឋកិច្ចឌីជីថល និងការវិនិយោគលើការប្រកួតប្រជែងនៅកម្ពុជា។

ចំណាយលើការទូទាត់ប្រាក់ខ្ចី ក្នុងឆ្នាំ ២០២២ ត្រូវបានគ្រោងចំនួន ១ ៤៧៧ ៦៥៧លានរៀល ត្រូវជា១,១៩%នៃ ផ.ស.ស. គឺមានកំណើន ២៤,៧% ធៀបនឹងច្បាប់ឆ្នាំ ២០២១ សម្រាប់រំលស់បំណុលសាធារណៈក្រៅប្រទេស។

ជារួម **ការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងនេះ និងការខ្ចីក្នុងទំហំខាងលើ នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌករដល់កម្ពុជាទេ**ពេលគឺជាទិដ្ឋភាពបច្ចេកទេស ស្ថានភាពបំណុលសាធារណៈកម្ពុជា នៅតែត្រូវបានវាយតម្លៃថាមាន «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**» ដដែលដោយរាល់សូចនាករបំណុលគន្លឹះៗ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។

## ក្រាហ្វិកទី៧៖ សន្និធិបំណុលសាធារណៈក្រៅប្រទេស គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ ២០២១




## អនុបាតបំណុលគន្លឹះទាំង ៤



## ជំពូក ៤

# សេចក្តីសន្និដ្ឋាន



# ៤ សេចក្តីសន្និដ្ឋាន

ថវិកាឆ្នាំ ២០២២ ត្រូវបានគិតគូរ និងរៀបចំឡើងក្នុងបរិការណ៍ដែលកម្ពុជាក៏ដូចជាពិភពលោកទាំងមូលកំពុងស្ថិតនៅកណ្តាលនៃវិបត្តិជំងឺកូវីដ-១៩ នៅឡើយដែលតម្រូវឱ្យរាជរដ្ឋាភិបាលតម្រង់ការប្រើប្រាស់ធនធានដើម្បី, ម្ខាង, ទ្រទ្រង់ដល់កិច្ចខិតខំប្រយុទ្ធនឹងជំងឺកូវីដ-១៩, ម្ខាងទៀត, ស្តារ និងជំរុញសេដ្ឋកិច្ចឱ្យបន្តស្ថិតនៅលើគន្លងនៃកំណើនខ្ពស់ និងរស់រវើកឡើងវិញ ព្រមទាំងស្តារជីវភាពរបស់ប្រជាជនទូទៅក៏ដូចជាដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗនៃ**កម្មវិធីនយោបាយ,យុទ្ធសាស្ត្រចតុកោណ -ដំណាក់កាលទី៤** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣** ពិសេសការជំរុញសម្ទុះល្បឿននៃការអនុវត្តកិច្ចការកែទម្រង់លើគ្រប់វិស័យក្នុងឆ្នាំ ២០២២ដែលជាឆ្នាំទី៤ នៃអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដើម្បីសំដៅកសាងមូលដ្ឋានគ្រឹះថ្មីៗបន្ថែម ក្នុងដំណើរឈានឆ្ពោះទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទនភាពជាតិមានអនាគតដ៏រុងរឿងភ្លឺស្វាង ត្រចះត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ ទន្ទឹមនេះក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ ក៏មានគោលដៅបន្តរក្សាការពារសមិទ្ធផលសង្គមជាតិទាំងឡាយ ដែលសម្រេចបានកន្លងមក ប្រកបដោយភាពជាម្ចាស់ ព្រមជាមួយនឹងការខិតខំប្រឹងប្រែងដើម្បីជម្នះ និង ទប់ទល់ផលប៉ះពាល់អវិជ្ជមាននានាបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងបញ្ហាប្រឈមផ្សេងៗទៀត ទាំងក្នុង និងក្រៅប្រទេសក្នុងស្មារតីធានាឱ្យកម្ពុជាអាចឈររឹងមាំ និងធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួន ទាំងនៅក្នុងពេលបច្ចុប្បន្ន និងតទៅអនាគត។

ក្របខ័ណ្ឌចំណាយថវិកាឆ្នាំ ២០២២ មានចរិតជាការប្រឹងប្រែងប្តូរផ្តាច់ ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដើម្បីការពារអាយុជីវិតរបស់ប្រជាជនផង និងកសាងមូលដ្ឋានដើម្បីសម្រាប់រស់នៅជាមួយនឹងជំងឺ កូវីដ-១៩ផងក្នុងគោលដៅស្តារសេដ្ឋកិច្ច និងស្តារជីវភាពប្រជាជនឡើងវិញតាមរយៈការបន្តអនុវត្តនូវកញ្ចប់អន្តរាគមន៍សង្គម-សេដ្ឋកិច្ច សំដៅបន្តគ្រប់គ្រងផលប៉ះពាល់ពីការរីករាលដាលនៃ

ជំងឺកូវីដ-១៩ បង្កើតការងារជូនប្រជាជន លើកកម្ពស់បរិយាកាសធុរកិច្ច តាមរយៈការផ្ដល់ការលើកទឹកចិត្ត និងបង្កើនទំនុកចិត្តវិនិយោគិន ការបន្តអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការពង្រឹងគុណភាពនៃសេវាសាធារណៈគ្រប់ប្រភេទ ការបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃស្ថាប័នសាធារណៈ ការលើកកម្ពស់សុខុមាលភាពប្រជាជន ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងការជំរុញការធ្វើបរិវត្តកម្មជីឌីថល ព្រមទាំងការ បន្តដោះស្រាយរាល់បញ្ហាប្រឈមជារចនាសម្ព័ន្ធនានា ដែលជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការលើក កម្ពស់ផលិតភាព ប្រសិទ្ធភាព និងភាពប្រកួតប្រជែងកម្ពុជា។

ទន្ទឹមនេះក្របខ័ណ្ឌចំណូលថវិកាឆ្នាំ ២០២២ ក៏បានគូសបញ្ជាក់នូវការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការខិតខំពង្រឹងការកៀរគរធនធានដែលនៅមានសក្ដានុពល ទាំងនៅលើផ្នែកចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ព្រមទាំងបន្ថែមការគិតគូរទៅលើយន្តការហិរញ្ញប្បទាននានាដើម្បីម្យ៉ាង បំពេញឱ្យបាននូវរាល់តម្រូវការចំណាយក្នុងបរិការណ៍វិបត្តិនៃជំងឺកូវីដ-១៩ និងម្យ៉ាងទៀតដើម្បីរក្សាឱ្យបានដាច់ ខាតនូវតុល្យភាពថវិកាដែលជាមូលដ្ឋានគ្រឹះក្នុងការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ។

សរុបមក, ថវិកាឆ្នាំ ២០២២ អាចត្រូវបានសន្និដ្ឋានជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង, ទាំងក្នុង និងក្រៅប្រទេស, សំដៅបន្តការពារអាយុជីវិត លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនពលរដ្ឋ ព្រមទាំងស្តារ និងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច ហើយអាចប្រសិទ្ធនាមបានថាជា “**ថវិកាសម្រាប់បន្តការប្រយុទ្ធប្រឆាំង និងការកសាងសមត្ថភាពរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ**”។

ជំពូក ៥

# ឧបសម្ព័ន្ធ



# ៥.១ គោលនយោបាយ និងថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ន

ឯកតា÷ លានរៀល

| កូដកម្មវិធី | តារាង១÷ គម្រោងចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| សរុបរួមចំណាយថវិកា (I+II) | | 3,040,826.0 |
| I. គោលបំណងគោលនយោបាយ÷ ១ - ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា, ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា | | 378,220.5 |
| 1 | កម្មវិធីទី១÷ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ | 276,882.1 |
| 101 | អនុកម្មវិធីទី១÷ការពង្រីកការអប់រំកុមារតូច | 11,695.2 |
| 102 | អនុកម្មវិធីទី២÷ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | 1,858.3 |
| 103 | អនុកម្មវិធីទី៣÷ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | 6,503.5 |
| 104 | អនុកម្មវិធីទី៤÷ការពង្រីកការអប់រំក្រៅប្រព័ន្ធ | 1,614.0 |
| 105 | អនុកម្មវិធីទី៥÷ការពង្រឹង និងការពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា | 767.1 |
| 106 | អនុកម្មវិធីទី៦÷លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស | 2,283.2 |
| 107 | អនុកម្មវិធីទី៧÷ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន | 1,438.9 |
| 108 | អនុកម្មវិធីទី៨÷ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ | 27,182.3 |
| 109 | អនុកម្មវិធីទី៩÷ពង្រីកការអប់រំបរិយាបន្នគ្រប់ភូមិសិក្សា | 571.0 |
| 110 | អនុកម្មវិធីទី១០÷ សេវាគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការរបស់មន្ទីរជំនាញរាជធានី ខេត្ត | 222,968.6 |
| 2 | កម្មវិធីទី២÷ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ | 28,042.4 |
| 201 | អនុកម្មវិធីទី១÷ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | 2,055.8 |
| 202 | អនុកម្មវិធីទី២÷ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា | 544.3 |
| 203 | អនុកម្មវិធីទី៣÷ ការពង្រឹងគុណភាព និងភាពឆ្លើយតបនៃការបណ្តុះបណ្តាលកម្រិតឧត្តម និងក្រោយឧត្តមប្រកបដោយប្រសិទ្ធភាព | 2,971.7 |
| 204 | អនុកម្មវិធីទី៤÷ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវ | 1,042.7 |
| 205 | អនុកម្មវិធីទី៥÷ ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | 1,902.1 |

| កូដ កម្មវិធី | តារាង១÷ គម្រោងចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 206 | អនុកម្មវិធីទី៦÷ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ | 3,363.7 |
| 207 | អនុកម្មវិធីទី៧÷ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូ និងស្រាវជ្រាវ | 3,718.4 |
| 208 | អនុកម្មវិធីទី៨÷ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | 2,458.2 |
| 209 | អនុកម្មវិធីទី៩÷ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ | 1,294.2 |
| 210 | អនុកម្មវិធីទី១០÷ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវ | 1,846.4 |
| 211 | អនុកម្មវិធីទី១១÷ លើកកម្ពស់គុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសហគ្រិនភាព | 0.0 |
| 212 | អនុកម្មវិធីទី១២÷ ការពង្រឹងគុណភាពប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវ | 0.0 |
| 213 | អនុកម្មវិធីទី១៣÷ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា | 565.5 |
| 214 | អនុកម្មវិធីទី១៤÷ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំ ការស្រាវជ្រាវ និងសេវាសហគមន៍លើផ្នែកបច្ចេកវិទ្យា | 1,564.9 |
| 215 | អនុកម្មវិធីទី១៥÷ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | 927.1 |
| 216 | អនុកម្មវិធីទី១៦÷ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវលើផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ | 1,159.5 |
| 217 | អនុកម្មវិធីទី១៧÷ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំគ្រូបង្រៀនឆ្លើយស្របតាមខណ្ឌគុណវុឌ្ឍិជាតិ | 1,324.5 |
| 218 | អនុកម្មវិធីទី១៨÷ ពង្រឹងគុណភាពបណ្តុះបណ្តាល វិក្រឹតការគ្រូ និងការស្រាវជ្រាវស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ | 1,303.4 |
| 3 | កម្មវិធីទី៣÷ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា | 59,715.7 |
| 301 | អនុកម្មវិធីទី១÷ ការអភិវឌ្ឍកីឡាមហាជន | 5,377.1 |
| 302 | អនុកម្មវិធីទី២÷ ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស និស្សិត | 2,261.4 |
| 303 | អនុកម្មវិធីទី៣÷ ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា | 1,030.7 |
| 304 | អនុកម្មវិធីទី៤÷ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ | 22,915.9 |
| 305 | អនុកម្មវិធីទី៥÷ ការអភិវឌ្ឍការប្រកួត និងគ្រប់គ្រងព្រឹត្តិការណ៍កីឡាគ្រប់កម្រិត | 10,063.9 |

| កូដ កម្មវិធី | តារាង១÷ គម្រោងចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 306 | អនុកម្មវិធីទី៦÷ ការអភិវឌ្ឍផ្នែកព័ត៌មាន និងស្ថិតិកីឡាគ្រប់ប្រភេទ | 348.8 |
| 307 | អនុកម្មវិធីទី៧÷ សេវាគាំទ្រការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡារបស់មន្ទីរជំនាញរាជធានី ខេត្ត | 17,717.9 |
| 4 | កម្មវិធីទី៤÷ ការអភិវឌ្ឍយុវជន | 13,580.3 |
| 401 | អនុកម្មវិធីទី១÷ ការអភិវឌ្ឍសកម្មភាពយុវជន | 5,489.2 |
| 402 | អនុកម្មវិធីទី២÷ ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន | 1,715.2 |
| 403 | អនុកម្មវិធីទី៣÷ ការអភិវឌ្ឍកាយវិទ្ធិកម្ម | 1,005.0 |
| 404 | អនុកម្មវិធីទី៤÷ សេវាគាំទ្រការអភិវឌ្ឍយុវជនរបស់មន្ទីរជំនាញរាជធានី ខេត្ត | 5,370.9 |
| **II. គោលបំណងគោលនយោបាយ ÷ ២ - ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធានាគុណភាពសក្តិសិទ្ធិនៃការដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់** | | **2,662,605.5** |
| 5 | កម្មវិធីទី៥÷ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ | 2,662,605.5 |
| 501 | អនុកម្មវិធីទី១÷ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំ | 925.2 |
| 502 | អនុកម្មវិធីទី២÷ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | 109,763.6 |
| 503 | អនុកម្មវិធីទី៣÷ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍនសមត្ថភាព ការគាំទ្រការលើកម្ពស់គុណភាពអប់រំ និងមូលដ្ឋានសម្ភារ | 80,583.4 |
| 504 | អនុកម្មវិធីទី៤÷ការពង្រឹងការងារសវនកម្មផ្ទៃក្នុង | 348.8 |
| 505 | អនុកម្មវិធីទី៥÷ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចប្រព័ន្ធធានាគុណភាពអប់រំ | 1,916.0 |
| 506 | អនុកម្មវិធីទី៦÷អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | 293.7 |
| 507 | អនុកម្មវិធីទី៧÷លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអប់រំ និងកិច្ចសហប្រតិបត្តិការអាស៊ាន និងស៊ីមេអូ | 752.3 |
| 508 | អនុកម្មវិធីទី៨÷ ការពង្រឹងការងារនីតិកម្ម | 422.2 |
| 509 | អនុកម្មវិធីទី៩÷ ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ | 4,047.6 |
| 510 | អនុកម្មវិធីទី១០÷ ការពង្រឹងការគ្រប់គ្រង ការផ្គត់ផ្គង់សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | 1,832.2 |
| 511 | អនុកម្មវិធីទី១១÷ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពសក្តិសិទ្ធនៃសេវារដ្ឋបាលអប់រំ | 1,853.1 |
| 512 | អនុកម្មវិធីទី១២÷ ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិលើវិស័យអប់រំ | 4,672.6 |
| 513 | អនុកម្មវិធីទី១៣÷ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | 827.1 |

| កូដ កម្មវិធី | តារាង១÷ គម្រោងចំណាយថវិកាក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 514 | អនុកម្មវិធីទី១៤÷ អភិវឌ្ឍគោលនយោបាយអប់រំ និងការស្រាវជ្រាវ | 1,193.5 |
| 515 | អនុកម្មវិធីទី១៥÷ អភិវឌ្ឍប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ | 406.2 |
| 516 | អនុកម្មវិធីទី១៦÷ ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធព័ត៌មានវិទ្យា | 594.7 |
| 517 | អនុកម្មវិធីទី១៧÷ ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សា និងអប់រំបច្ចេកទេស | 0.0 |
| 518 | អនុកម្មវិធីទី១៨÷ សេវាគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ របស់មន្ទីរជំនាញរាជធានី ខេត្ត | 2,452,173.3 |

| កូដ កម្មវិធី | តារាង២÷ គម្រោងចំណាយថវិកាក្រសួងសុខាភិបាលតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| គោលបំណងគោលនយោបាយ÷ លើកកម្ពស់លទ្ធផលសុខភាពប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង និងបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាថែទាំសុខភាព | | |
| សរុបរួមចំណាយថវិកា | | 1,341,377.0 |
| 1 | កម្មវិធីទី១ ÷ សុខភាពបន្តពូជ យុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ | 110,138.9 |
| 101 | អនុកម្មវិធីទី១ ÷ អាហារូបត្ថម្ភ | 829.1 |
| 102 | អនុកម្មវិធីទី២ ÷ សុខភាពបន្តពូជ | 9,003.3 |
| 103 | អនុកម្មវិធីទី៣ ÷ សុខភាពមាតា និងទារក | 6,133.0 |
| 104 | អនុកម្មវិធីទី៤ ÷ សុខភាពកុមារ | 94,173.5 |
| 2 | កម្មវិធីទី២ ÷ ប្រយុទ្ធជំងឺឆ្លង | 26,958.1 |
| 201 | អនុកម្មវិធីទី១ ÷ បង្ការ និងថែទាំព្យាបាលជំងឺអេដស៍ | 16,090.7 |
| 202 | អនុកម្មវិធីទី២ ÷ បង្ការ និងថែទាំព្យាបាលជំងឺរបេង | 9,017.8 |
| 203 | អនុកម្មវិធីទី៣ ÷ បង្ការ និងថែទាំព្យាបាលជំងឺគ្រុនចាញ់ និងគ្រុនឈាម | 1,228.9 |
| 204 | អនុកម្មវិធីទី៤ ÷ បង្ការ និងឆ្លើយតបជំងឺឆ្លងដទៃទៀត | 620.7 |
| 3 | កម្មវិធីទី៣ ÷ ប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត | 1,543.3 |
| 301 | អនុកម្មវិធីទី១ ÷ សុខភាពភ្នែក | 100.0 |
| 302 | អនុកម្មវិធីទី២ ÷ សុខភាពផ្លូវចិត្ត និងបំពានគ្រឿងញៀន | 472.6 |
| 303 | អនុកម្មវិធីទី៣ ÷ សុខភាពមាត់-ធ្មេញ | 107.3 |

| កូដ កម្មវិធី | តារាង២÷ គម្រោងចំណាយថវិកាក្រសួងសុខាភិបាលតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 304 | អនុកម្មវិធីទី៤ ÷ ជំងឺរ៉ាំរ៉ៃ | 51.9 |
| 305 | អនុកម្មវិធីទី៥ ÷ បញ្ហាសុខភាពសាធារណៈផ្សេងៗទៀត | 811.5 |
| 4 | កម្មវិធីទី៤ ÷ ពង្រឹងប្រព័ន្ធសុខាភិបាល | 1,202,736.7 |
| 401 | អនុកម្មវិធីទី១ ÷ ការផ្តល់សេវាសុខាភិបាល | 1,067,411.3 |
| 402 | អនុកម្មវិធីទី២ ÷ ហិរញ្ញប្បទានសុខាភិបាល | 5,861.8 |
| 403 | អនុកម្មវិធីទី៣ ÷ អភិវឌ្ឍន៍ធនធានមនុស្ស | 114,178.7 |
| 404 | អនុកម្មវិធីទី៤ ÷ ប្រព័ន្ធព័ត៌មានសុខាភិបាល | 126.0 |
| 405 | អនុកម្មវិធីទី៥ ÷ អភិបាលកិច្ចវិស័យសុខាភិបាល | 2,881.9 |
| 406 | អនុកម្មវិធីទី៦ ÷ សេវាគាំទ្រពង្រឹងប្រព័ន្ធសុខាភិបាលសម្រាប់សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | 12,277.0 |

| កូដ កម្មវិធី | តារាង៣÷ គម្រោងចំណាយថវិកាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| **គោលបំណងគោលនយោបាយ÷ ពង្រឹងប្រព័ន្ធគាំពារសង្គម និងផ្តល់សេវាសុខុមាលភាពសង្គម ប្រកបដោយប្រសិទ្ធភាព និងសមធម៌** | | 1,412,862.0 |
| សរុបរួមចំណាយថវិកា | | 1,412,862.0 |
| 1 | កម្មវិធីទី ១ ÷ សេវាសុខុមាលភាពសង្គម | 73,631.0 |
| 101 | អនុកម្មវិធីទី ១ ÷ ការផ្តល់សេវាសុខុមាលភាពប្រជាជនក្រីក្រនិងជនរងគ្រោះនៅតាមសហគមន៍ | 42,561.2 |
| 102 | អនុកម្មវិធីទី ២ ÷ កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងរំលោភបំពានផ្លូវភេទ | 57.8 |
| 103 | អនុកម្មវិធីទី ៣ ÷ ការផ្តល់សេវាសុខុមាលភាពនិង កិច្ចការពារកុមារ | 1,105.0 |
| 104 | អនុកម្មវិធីទី ៤ ÷ កិច្ចការពារអនីតិជនទំនាស់នឹងច្បាប់ និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន | 3,507.7 |
| 105 | អនុកម្មវិធីទី ៥ ÷ ការផ្តល់សេវាសុខុមាលភាព និងកិច្ចការពារជនមានពិការភាព | 1,407.2 |
| 106 | អនុកម្មវិធីទី ៦ ÷ កិច្ចគាំពារសុខុមាលភាពមនុស្សចាស់ | 176.9 |
| 107 | អនុកម្មវិធីទី ៧ ÷ កិច្ចគាំពារអតីតយុទ្ធជន និងការគ្រប់គ្រងសកម្មភាពផ្តល់សេវាសុខុមាលភាពសង្គម | 4,391.2 |

| កូដ កម្មវិធី | តារាង៣÷ គម្រោងចំណាយថវិកាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 108 | អនុកម្មវិធីទី ៨ ÷ សេវាគាំទ្រសេវាសុខុមាលភាពសង្គមដោយរាជធានី ខេត្ត | 20,424.0 |
| 2 | កម្មវិធីទី ២ ÷ ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ | 1,276,737.0 |
| 201 | អនុកម្មវិធីទី ១ ÷អភិវឌ្ឍន៍របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល | 504,258.0 |
| 202 | អនុកម្មវិធីទី ២ ÷ ការផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន | 762,864.0 |
| 203 | អនុកម្មវិធីទី ៣ ÷ ស្តារលទ្ធភាពពលកម្មកាយសម្បទា និងការគាំទ្រមុខរបរជនពិការ | 9,615.0 |
| 3 | កម្មវិធីទី ៣ ÷ ការគ្រប់គ្រងស្ថាប័ន និងកិច្ចការរដ្ឋបាលទូទៅ | 62,494.0 |
| 301 | អនុកម្មវិធីទី ១ ÷ ការពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការភាពជាដៃគូ | 30,635.0 |
| 302 | អនុកម្មវិធីទី ២ ÷ អភិវឌ្ឍភាពធនធានមនុស្ស | 319.0 |
| 303 | អនុកម្មវិធីទី ៣ ÷ សេវាគាំទ្រការគ្រប់គ្រងស្ថាប័ន និងកិច្ចការរដ្ឋបាលទូទៅដោយរាជធានី ខេត្ត | 31,540.0 |

| កូដ កម្មវិធី | តារាង៤÷ គម្រោងចំណាយថវិកាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| | **គោលបំណងគោលនយោបាយ÷ ការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | |
| សរុបរួមចំណាយថវិកា | | 233,893.0 |
| 1 | កម្មវិធីទី១÷ ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ | 16,059.7 |
| 101 | អនុកម្មវិធីទី១÷ លើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង | 3,347.4 |
| 103 | អនុកម្មវិធីទី៣÷ ទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ | 1,080.0 |
| 104 | អនុកម្មវិធីទី៤÷ ពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត | 1,000.0 |
| 105 | អនុកម្មវិធីទី៥÷ ពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ | 9,229.9 |
| 106 | អនុកម្មវិធីទី៦÷ សេវាគាំទ្រការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 1,402.4 |
| 2 | កម្មវិធីទី២÷ ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | 54,029.4 |
| 201 | អនុកម្មវិធីទី១÷ ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | 36,646.7 |

| កូដ កម្មវិធី | តារាង៤÷ គម្រោងចំណាយថវិកាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 202 | អនុកម្មវិធីទី២÷ ពង្រីកការបណ្តុះបណ្តាលជំនាញដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម | 16,097.5 |
| 203 | អនុកម្មវិធីទី៣÷ ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូនានា ដើម្បីធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | 217.4 |
| 204 | អនុកម្មវិធីទី៤÷ លើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | 656.5 |
| 205 | អនុកម្មវិធីទី៥÷ ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍ | 120.5 |
| 206 | អនុកម្មវិធីទី៦÷ សេវាគាំទ្រការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 290.8 |
| 3 | កម្មវិធីទី៣ ÷ ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុង និងក្រៅប្រទេស | 3,996.5 |
| 301 | អនុកម្មវិធីទី១÷ បង្កើនឱកាសការងារសមរម្យ និងផលិតភាពការងារខ្ពស់ | 23.1 |
| 302 | អនុកម្មវិធីទី២÷ ពង្រីកយន្តការវិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារឱ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា | 1,700.0 |
| 303 | អនុកម្មវិធីទី៣÷ពង្រឹងយន្តការវេទិកាការងារ និងបង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជាបព័ត៌មានទីផ្សារការងារ | 1,630.0 |
| 304 | អនុកម្មវិធីទី៤÷ ពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ | 73.4 |
| 305 | អនុកម្មវិធីទី៥÷ បង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងស្ថិតក្នុងទីផ្សារការងារ | 570.0 |
| 5 | កម្មវិធីទី៥÷ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ | 159,807.4 |
| 501 | អនុកម្មវិធីទី១÷ ពង្រឹងការងាររដ្ឋបាល វិមជ្ឈការ និងវិសហមជ្ឈការដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ | 69,599.4 |
| 502 | អនុកម្មវិធីទី២÷ ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន | 28,294.6 |
| 503 | អនុកម្មវិធីទី៣÷ អភិវឌ្ឍសមត្ថភាពមន្រ្តីរាជការ និងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 2,609.1 |
| 504 | អនុកម្មវិធីទី៤÷ ពង្រឹងកិច្ចសហប្រតិបត្តិការ សមភាពយេនឌ័រ និងសេវាសង្គម | 4,093.4 |
| 505 | អនុកម្មវិធីទី៥÷ ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរបស់ក្រសួង និងគោលន័យោបាយនានាពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 165.1 |
| 506 | អនុកម្មវិធីទី៦÷ សេវាគាំទ្រទូទៅរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 55,045.8 |

| កូដ កម្មវិធី | តារាង៥÷ គម្រោងចំណាយថវិកាក្រសួងបរិស្ថានតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| **គោលបំណងគោលនយោបាយ÷ កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍដោយ ចីរភាព** | | |
| សរុបរួមចំណាយថវិកា | | 80,849.0 |
| 1 | ១. កម្មវិធីទី១÷ កិច្ចគាំពារបរិស្ថាន | 1,588.7 |
| 101 | អនុកម្មវិធីទី១÷ ការត្រួតពិនិត្យ តាមដាន គុណភាពបរិស្ថាន (គុណភាពទឹក ដី ខ្យល់) | 48.1 |
| 102 | អនុកម្មវិធីទី២÷ ការត្រួតពិនិត្យការបំពុលបរិស្ថាន (ដោយសំណល់រឹង រាវ សារធាតុគ្រោះថ្នាក់ ផ្សែង សំឡេង រំញ័រ) | 115.6 |
| 103 | អនុកម្មវិធីទី៣÷ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | 125.4 |
| 104 | អនុកម្មវិធីទី៤÷ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន | 1,038.9 |
| 105 | អនុកម្មវិធីទី៥ ÷ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន សម្រាប់មន្ទីរបរិស្ថាន | 260.7 |
| 2 | ២. កម្មវិធីទី២ ÷ ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន | 5,609.1 |
| 201 | អនុកម្មវិធីទី១÷ សេវាគាំទ្រការងារគ្រប់គ្រង និងពង្រឹងការអនុវត្តច្បាប់ | 1,481.4 |
| 202 | អនុកម្មវិធីទី២÷ ការគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ | 679.4 |
| 203 | អនុកម្មវិធីទី៣÷ សេវាគាំទ្រការងារគ្រប់គ្រងសហគមន៍មូលដ្ឋាន | 1,279.6 |
| 204 | អនុកម្មវិធីទី៤÷ ការអភិរក្សបេតិកភណ្ឌ ធម្មជាតិតវប្បធម៌ | 194.7 |
| 205 | អនុកម្មវិធីទី៥÷ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងសហគមន៍មូលដ្ឋាន | 182.9 |
| 206 | អនុកម្មវិធីទី ៦ ÷ សេវាគាំទ្រការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន របស់មន្ទីរបរិស្ថាន | 1,791.1 |
| 3 | ៣. កម្មវិធីទី៣ ÷ ការគ្រប់គ្រងការអភិវឌ្ឍន៍ដោយចីរភាព | 839.7 |
| 301 | អនុកម្មវិធីទី១÷ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងការលើកកម្ពស់ ការអនុវត្តវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា | 530.2 |
| 302 | អនុកម្មវិធីទី២÷ ជំរុញការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | 60.5 |
| 303 | អនុកម្មវិធីទី៣ ÷ ការអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព | 228.3 |
| 304 | អនុកម្មវិធីទី៤ ÷ សេវាគាំទ្រការគ្រប់គ្រងការអភិវឌ្ឍន៍ដោយចីរភាពរបស់មន្ទីរបរិស្ថាន | 20.7 |
| 4 | ៤. កម្មវិធីទី៤ ÷ ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន | 1,664.7 |
| 401 | អនុកម្មវិធីទី១÷ ការលើកកម្ពស់ចំណេះដឹង និងមេត្រីភាពបរិស្ថាន | 214.2 |

| កូដ កម្មវិធី | តារាង៥÷ គម្រោងចំណាយថវិកាក្រសួងបរិស្ថានតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 402 | អនុកម្មវិធីទី២÷ គ្រប់គ្រងទិន្នន័យភូមិសាស្រ្ត និងព័ត៌មានបរិស្ថាន | 554.7 |
| 403 | អនុកម្មវិធីទី៣÷ សេវាកម្មគាំទ្រការងារគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន | 543.1 |
| 404 | អនុកម្មវិធីទី៤ ÷ សេវាគាំទ្រការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន របស់មន្ទីរបរិស្ថាន | 352.7 |
| 5 | ៥. កម្មវិធីទី៥ ÷ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ | 71,146.8 |
| 501 | អនុកម្មវិធីទី១÷ ការគ្រប់គ្រងការងាររដ្ឋបាល និងខុទ្ទកាល័យ | 351.7 |
| 502 | អនុកម្មវិធីទី២÷ ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស | 20,670.6 |
| 503 | អនុកម្មវិធីទី៣÷ ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | 8,260.0 |
| 504 | អនុកម្មវិធីទី៤÷ ការងារផែនការ និងការងារសង្គមក្នុងវិស័យបរិស្ថាន | 473.5 |
| 505 | អនុកម្មវិធីទី៥÷ ការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង | 167.2 |
| 506 | អនុកម្មវិធីទី៦ ÷ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ របស់មន្ទីរបរិស្ថាន | 41,223.8 |

| កូដ កម្មវិធី | តារាង៦÷ គម្រោងចំណាយថវិកាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| **គោលបំណងគោលនយោបាយ ÷ អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ** | | |
| សរុបរួមចំណាយថវិកា | | 158,060.0 |
| 1 | កម្មវិធីទី ១ ÷ កិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី | 1,495.9 |
| 101 | អនុកម្មវិធីទី ១ ÷ ការបង្កើនកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌រូបី | 654.0 |
| 102 | អនុកម្មវិធីទី ២ ÷ ការលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌រូបី | 467.0 |
| 103 | អនុកម្មវិធីទី ៣ ÷ សេវាគាំទ្រកិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី ថ្នាក់រាជធានី ខេត្ត | 374.9 |
| 2 | កម្មវិធីទី ២ ÷ ការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី | 2,379.7 |
| 201 | អនុកម្មវិធីទី ១ ÷ ការពង្រឹងកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី | 180.0 |
| 202 | អនុកម្មវិធីទី ២ ÷ ការលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី | 1,694.0 |
| 203 | អនុកម្មវិធីទី ៣ ÷ សេវាគាំទ្រការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី | 505.7 |
| 3 | កម្មវិធីទី ៣ ÷ការគ្រប់គ្រងស្ថាប័ន និងកិច្ចការរដ្ឋបាលទូទៅ | 154,184.4 |

| កូដ កម្មវិធី | តារាង៦÷ គម្រោងចំណាយថវិកាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 301 | អនុកម្មវិធីទី ១ ÷ ការពង្រឹងអភិបាលកិច្ច | 51,708.0 |
| 302 | អនុកម្មវិធីទី ២ ÷ ការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យវប្បធម៌ (សាលាមធ្យមវិចិត្រសិល្បៈ) | 2,769.0 |
| 303 | អនុកម្មវិធីទី ៣ ÷ ការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យវប្បធម៌ (សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ) | 2,097.4 |
| 304 | អនុកម្មវិធីទី ៤ ÷ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ (អាជ្ញាធរជាតិសំបូរព្រៃគុក) | 3,006.8 |
| 305 | អនុកម្មវិធីទី ៥÷ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ (អាជ្ញាធរជាតិព្រះវិហារ) | 6,217.6 |
| 306 | អនុកម្មវិធីទី ៦÷ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ ( អាជ្ញាធរជាតិអប្សរា) | 58,298.1 |
| 307 | អនុកម្មវិធីទី ៧ ÷ ការពង្រឹងយន្តការការងាររបស់គណៈកម្មាធិការជាតិបេតិភណ្ឌពិភពលោក | 334.1 |
| 308 | អនុកម្មវិធីទី ៨ ÷ ការពង្រឹងយន្តការការងាររបស់គណៈកម្មការជាតិយូណេស្កូកម្ពុជា | 270.0 |
| 309 | អនុកម្មវិធីទី ៩ ÷ សេវាគាំទ្រ ការគ្រប់គ្រងស្ថាប័ន និងកិច្ចការរដ្ឋបាលទូទៅ ថ្នាក់រាជធានី ខេត្ត | 29,483.4 |

| កូដ កម្មវិធី | តារាង៧÷ គម្រោងចំណាយថវិកាក្រសួងព័ត៌មានតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| **គោលបំណងគោលនយោបាយ÷ ការលើកកម្ពស់សេវាព័ត៌មាន ធានាឱ្យបាននូវសិទ្ធិទទួលបានព័ត៌មានពេញលេញ ទាន់ពេលវេលា និងសុក្រឹត្យ** | | |
| សរុបរួមចំណាយថវិកា | | 76,054.0 |
| 1 | កម្មវិធីទី ១ ÷ ការគ្រប់គ្រង និងអភិវឌ្ឍវិស័យព័ត៌មាន | 76,054.0 |
| 101 | អនុកម្មវិធីទី ១ ÷ កិច្ចការព័ត៌មាន និងសោតទស្សន៍ | 753.8 |
| 102 | អនុកម្មវិធីទី ២ ÷ ការងារផ្សព្វផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជា | 1,153.0 |
| 103 | អនុកម្មវិធីទី ៣ ÷ ការងារផ្សព្វផ្សាយរបស់វិទ្យុជាតិកម្ពុជា | 953.1 |
| 104 | អនុកម្មវិធីទី ៤ ÷ ការងារផ្សព្វផ្សាយរបស់ទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP | 675.3 |
| 105 | អនុកម្មវិធីទី ៥ ÷ កិច្ចការរដ្ឋបាលទូទៅ | 47,319.8 |
| 106 | អនុកម្មវិធីទី ៦ ÷ សេវាគាំទ្រលើកកម្ពស់វិស័យព័ត៌មានរបស់មន្ទីរជំនាញរាជធានី ខេត្ត | 25,199.0 |

| កូដ កម្មវិធី | តារាង៨÷ គម្រោងចំណាយថវិកាក្រសួងកិច្ចការនារីតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| | **គោលបំណងគោលនយោបាយ÷ "ប្រែក្លាយស្ត្រីជាកម្លាំងចលករ ដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយរបស់ស្ត្រី ឱ្យមានការប្រែប្រួលល្អប្រសើរជាលំដាប់ ដើម្បីសុភមង្គលគ្រួសារ"** | |
| | សរុបរួមចំណាយថវិកា | 43,074.0 |
| 1 | កម្មវិធីទី១÷ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ស្ត្រី | 5,686.0 |
| 101 | អនុកម្មវិធីទី១÷ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ | 165.4 |
| 102 | អនុកម្មវិធីទី២÷ លើកកម្ពស់ការអប់រំ និងសុខុមាលភាពសង្គម | 269.3 |
| 103 | អនុកម្មវិធីទី៣÷ អភិវឌ្ឍន៍សេដ្ឋកិច្ចស្ត្រី និងគ្រួសារ | 3,786.4 |
| 104 | អនុកម្មវិធីទី៤÷ ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងកុមារ | 163.2 |
| 105 | អនុកម្មវិធីទី៥÷ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ស្ត្រី ថ្នាក់រាជធានី-ខេត្ត | 1,301.7 |
| 2 | កម្មវិធីទី២÷ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី | 1,552.4 |
| 201 | អនុកម្មវិធីទី១÷ ទប់ស្កាត់ការរំលោភបំពានលើស្ត្រី | 185.9 |
| 202 | អនុកម្មវិធីទី២÷ ពង្រឹងសមត្ថភាពមន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌ | 124.5 |
| 203 | អនុកម្មវិធីទី៣÷ ទប់ស្កាត់គ្រឿងញៀន និងអំពើជួញដូរមនុស្ស | 351.3 |
| 204 | អនុកម្មវិធីទី៤÷ ទប់ស្កាត់អំពើហិង្សាលើស្ត្រី | 200.0 |
| 205 | អនុកម្មវិធីទី៥÷ លើកកម្ពស់កិច្ចការពារស្ត្រីពិការ | 168.7 |
| 206 | អនុកម្មវិធីទី៦÷ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី ថ្នាក់រាជធានី-ខេត្ត | 522.0 |
| 3 | កម្មវិធីទី៣÷ ការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយជាតិ និងតាមវិស័យ | 2,478.2 |
| 301 | អនុកម្មវិធីទី១÷ អភិវឌ្ឍសមត្ថភាពស្តីពី ការបញ្ជ្រាបយេនឌ័រ | 115.6 |
| 302 | អនុកម្មវិធីទី២÷ ផ្សព្វផ្សាយកម្មវិធីនារីរតនៈ | 596.9 |
| 303 | អនុកម្មវិធីទី៣÷ ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (CEDAW) | 860.1 |
| 304 | អនុកម្មវិធីទី៤÷ ស្ត្រី និងការធ្វើសេចក្តីសម្រេច | 117.3 |
| 305 | អនុកម្មវិធីទី៥÷ ការបញ្ជ្រាបយេនឌ័រក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | 108.5 |
| 306 | អនុកម្មវិធីទី៦÷ លើកកម្ពស់សមភាពយេនឌ័រ ថ្នាក់រាជធានី-ខេត្ត | 679.8 |
| 4 | កម្មវិធីទី៤÷ ការគ្រប់គ្រង និងការអភិវឌ្ឍស្ថាប័ន | 33,357.4 |
| 401 | អនុកម្មវិធីទី១÷ ការរៀបចំផែនការស្ថិតិ និងការត្រួតពិនិត្យវាយតម្លៃឆ្លើយតបនឹងយេនឌ័រ | 178.8 |

| កូដ កម្មវិធី | តារាង៨÷ គម្រោងចំណាយថវិកាក្រសួងកិច្ចការនារីតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 402 | អនុកម្មវិធីទី២÷ ពង្រឹងការងារហិរញ្ញវត្ថុសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | 162.7 |
| 403 | អនុកម្មវិធីទី៣÷ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសមភាពយេនឌ័រ | 185.9 |
| 404 | អនុកម្មវិធីទី៤÷ អភិវឌ្ឍន៍សមត្ថភាពលើការងារគ្រប់គ្រងរដ្ឋបាល | 236.9 |
| 405 | អនុកម្មវិធីទី៥÷ សេវាគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ | 9,702.6 |
| 406 | អនុកម្មវិធីទី៦÷ សេវាគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ ថ្នាក់រាជធានី-ខេត្ត | 22,890.5 |

| កូដ កម្មវិធី | តារាង៩÷ គម្រោងចំណាយថវិកាក្រសួងធម្មការ និងសាសនាតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| | **គោលបំណងគោលនយោបាយ ÷ លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា** | |
| | សរុបរួមចំណាយថវិកា | 64,818.0 |
| 1 | កម្មវិធីទី ១ ÷ សុខដុមនីយកម្មសាសនានៅកម្ពុជា | 64,818.0 |
| 101 | អនុកម្មវិធីទី ១ ÷ ការអប់រំវិស័យពុទ្ធិកសិក្សា | 5,185.9 |
| 102 | អនុកម្មវិធីទី ២ ÷ ការផ្សព្វផ្សាយព្រះពុទ្ធសាសនា និងរក្សាសុខដុមនីយកម្មខាងជំនឿសាសនា | 1,408.3 |
| 103 | អនុកម្មវិធីទី ៣ ÷ កិច្ចការរដ្ឋបាលទូទៅ | 18,293.8 |
| 104 | អនុកម្មវិធីទី ៤ ÷ សេវាគាំទ្រទូទៅរាជធានី ខេត្ត | 39,930.0 |

| កូដ កម្មវិធី | តារាង១០÷ គម្រោងចំណាយថវិកាក្រសួងទេសចរណ៍តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| គោលបំណងគោលនយោបាយ÷ "ជំរុញកំណើនទេសចរណ៍ និងបង្កើនតម្លៃបន្ថែមតាមរយៈវិស័យទេសចរណ៍នៅកម្ពុជា" | | |
| សរុបរួមចំណាយថវិកា | | 74,578.0 |
| 1 | កម្មវិធីទី១÷ ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ | 4,308.2 |
| 101 | អនុកម្មវិធីទី១÷ ពង្រឹងគុណភាពឧស្សាហកម្មនិងសេវាកម្មទេសចរណ៍ “សេវាមួយស្តង់ដារមួយ” | 1,319.2 |
| 102 | អនុកម្មវិធីទី២÷ ការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ “បុគ្គលិកមួយ ជំនាញមួយ” | 696.0 |
| 103 | អនុកម្មវិធីទី៣÷ ជំរុញទេសចរណ៍ក្នុងស្រុក និងការយល់ដឹងសាធារណៈ | 423.0 |
| 104 | អនុកម្មវិធីទី៤÷ ជំរុញចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" | 1,088.0 |
| 105 | អនុកម្មវិធីទី៥÷ ពង្រឹងការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍និងការប្រឡងប្រណាំងនៅរាជធានី-ខេត្ត | 782.0 |
| 2 | កម្មវិធីទី២÷ ការអភិវឌ្ឍទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ | 9,917.8 |
| 201 | អនុកម្មវិធីទី១÷ ផែនការ ការអភិវឌ្ឍផលិតផល និងវិនិយោគទេសចរណ៍ | 3,153.8 |
| 202 | អនុកម្មវិធីទី២÷ ពង្រឹងនិងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការទេសចរណ៍ | 1,570.0 |
| 203 | អនុកម្មវិធីទី៣÷ ការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស | 3,610.0 |
| 204 | អនុកម្មវិធីទី៤÷ ពង្រឹងគុណភាពប្រព័ន្ធស្ថិតិទេសចរណ៍ និងការសិក្សាស្រាវជ្រាវរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងការគ្រប់គ្រងស្ថិតិទេសចរណ៍ | 188.0 |
| 205 | អនុកម្មវិធីទី៥÷ ផែនការ ការអភិវឌ្ឍផលិតផល និងវិនិយោគទេសចរណ៍រាជធានី-ខេត្ត | 1,396.0 |
| 3 | កម្មវិធីទី៣÷ សេវាគាំទ្រដំណើរការទូទៅរបស់ស្ថាប័ន | 60,352.0 |
| 301 | អនុកម្មវិធីទី១÷ បង្កើនប្រសិទ្ធភាព និងគុណភាពសេវារដ្ឋបាលសាធារណៈ សម្រួលការធ្វើដំណើរការដឹកជញ្ជូន និងសន្តិសុខ សុវត្ថិភាពទេសចរណ៍ | 244.0 |
| 302 | អនុកម្មវិធីទី២÷ ការគ្រប់គ្រងនិងអភិវឌ្ឍន៍សមត្ថភាពមន្ត្រី | 17,596.0 |
| 303 | អនុកម្មវិធីទី៣÷ ការគ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុ | 4,589.0 |
| 304 | អនុកម្មវិធីទី៤÷ ការកសាង និងអនុវត្តបទដ្ឋានគតិយុត្ត ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | 348.0 |
| 305 | អនុកម្មវិធីទី៥÷ កិច្ចការសម្របសម្រួលអន្តរវិស័យ | 193.0 |
| 306 | អនុកម្មវិធីទី៦÷ ការគ្រប់គ្រងការប្រមូលចំណូលពីរមណីយដ្ឋានអង្គរ | 16,049.0 |
| 307 | អនុកម្មវិធីទី៧÷ កិច្ចការគាំទ្រទេសចរណ៍ រាជធានី-ខេត្ត | 21,333.0 |

| កូដ កម្មវិធី | តារាង១១÷ គម្រោងចំណាយថវិកាក្រសួងធនធានទឹក និងឧតុនិយម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| **គោលបំណងគោលនយោបាយ÷ "ការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្ស ធនធានទឹកប្រកប ដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងនិរន្តរភាព"** | | |
| សរុបរួមចំណាយថវិកា | | 278,317.0 |
| 1 | កម្មវិធីទី១÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក | 214,392.0 |
| 101 | អនុកម្មវិធីទី១÷ កិច្ចដំណើរការ និងការជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រ (ន. ធារាសាស្ត្រកសិកម្ម) | 74,056.0 |
| 102 | អនុកម្មវិធីទី២÷ ស្តារ ជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ (ន. វិស្វកម្ម) | 120,057.0 |
| 103 | អនុកម្មវិធីទី៣÷ ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (ន. សហគមន៍កសិករប្រើប្រាស់ទឹក) | 38.0 |
| 104 | អនុកម្មវិធីទី៤÷ ការគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹកប្រកបដោយនិរន្តរភាព (ន. សហគមន៍កសិករប្រើប្រាស់ទឹក) | 8,026.0 |
| 105 | អនុកម្មវិធីទី៥÷ ការលើកកម្ពស់ការយល់ដឹង ការផ្សព្វផ្សាយ រួមទាំងការ សិក្សាស្រាវជ្រាវ ការរៀបចំ អនុវត្ត និងវាយតម្លៃសកម្មភាព នឹងគម្រោងពាក់ព័ន្ធ (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | 620.0 |
| 106 | អនុកម្មវិធីទី៦÷ ការលើកកម្ពស់ប្រសិទ្ធភាពការងារសម្របសម្រួល និងការពង្រឹង កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ (គណៈកម្មាធិការ ជាតិទន្លេមេគង្គកម្ពុជា) | 800.0 |
| 107 | អនុកម្មវិធីទី៧÷ សេវាគាំទ្រកិច្ចដំណើរការ ការជួសជុល និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្ររបស់មន្ទីរជំនាញរាជធានី-ខេត្ត | 10,795.0 |
| 2 | កម្មវិធីទី២÷ ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត | 3,564.0 |
| 201 | អនុកម្មវិធីទី១÷ ការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ និងទប់ទល់គ្រោះធម្មជាតិ (ន. ធារាសាស្ត្រកសិកម្ម) | 1,682.0 |
| 202 | អនុកម្មវិធីទី២÷ សាងសង់ ជួសជុល និងថែទាំម៉ាស៊ីនបូមទឹកចល័ត និងស្ថានីយបូមទឹក (ន. ធារាសាស្ត្រកសិកម្ម) | 807.0 |
| 203 | អនុកម្មវិធីទី៣÷ ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត របស់មន្ទីរជំនាញរាជធានី-ខេត្ត | 1,075.0 |
| 3 | កម្មវិធីទី៣÷ ការការពារ និងអភិរក្សធនធានទឹក | 2,261.0 |
| 301 | អនុកម្មវិធីទី១÷ ការគ្រប់គ្រងធនធានទឹកចំរុះ និងអាងទន្លេប្រកបដោយនិរន្តរភាព (ន. គ្រប់គ្រង និងអភិរក្សធនធានទឹក) | 61.0 |
| 302 | អនុកម្មវិធីទី២÷ សម្របសម្រួលការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបក្នុងស្មារតី ការការពារប្រព័ន្ធអេកូឡូស៊ីជីវចម្រុះនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធនៅ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ (អាជ្ញាធរទន្លេសាប) | 2,200.0 |

| កូដ កម្មវិធី | តារាង១១÷ គម្រោងចំណាយថវិកាក្រសួងធនធានទឹក និងឧតុនិយម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 4 | កម្មវិធីទី៤÷ ការគ្រប់គ្រងព័ត៌មានស្ដីពីធនធានទឹក និងឧតុនិយម | 2,182.0 |
| 401 | អនុកម្មវិធីទី១÷ រៀបចំចងក្រង គ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិរបស់ក្រសួង សម្រាប់លើកផែនការអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយមរយៈពេលខ្លី មធ្យម និងវែង លើគ្រប់ផ្នែកទាំងអស់ក្នុងក្របខណ្ឌទូទាំងប្រទេស (ន.ផែនការ និងសហប្រតិបត្តិការអន្តរជាតិ) | 62.0 |
| 402 | អនុកម្មវិធីទី២÷ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជលសាស្ត្រ ការគ្រប់គ្រងច្រាំងទន្លេ និងការត្រួតពិនិត្យគុណភាពទឹក (ន.ជលសាស្ត្រ និងការងារទន្លេ) | 339.0 |
| 403 | អនុកម្មវិធីទី៣÷ គ្រប់គ្រងព័ត៌មានឧតុនិយមប្រកបដោយប្រសិទ្ធភាព (ន.ឧតុនិយម) | 1,442.0 |
| 404 | អនុកម្មវិធីទី៤÷ ការគ្រប់គ្រងធនធានទឹកក្រោមដី និងការសិក្សាស្រាវជ្រាវចងក្រងទិន្នន័យទឹកក្រោមដី (ន.ទឹកស្អាត និងអនាម័យ) | 220.0 |
| 405 | អនុកម្មវិធីទី៥÷ គាំទ្រសេវាការគ្រប់គ្រងប្រព័ន្ធទិន្នន័យឧតុនិយម និងជលសាស្ត្ររបស់មន្ទីរជំនាញរាជធានី-ខេត្ត | 119.0 |
| 5 | កម្មវិធីទី៥÷ កិច្ចការរដ្ឋបាលទូទៅ | 55,918.0 |
| 501 | អនុកម្មវិធីទី១÷ ការកែលម្អការគ្រប់គ្រងរដ្ឋបាល និងការកសាងអភិវឌ្ឍន៍សមត្ថភាពមន្ត្រី (ន.រដ្ឋបាល និងធនធានមនុស្ស) | 419.0 |
| 502 | អនុកម្មវិធីទី២÷ ការរៀបចំផែនការគោលនយោបាយយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម (ន.ផែនការ និងសហប្រតិបត្តិការអន្តរជាតិ) | 244.0 |
| 503 | អនុកម្មវិធីទី៣÷ បង្កើនប្រសិទ្ធភាពការគ្រប់គ្រង និងការអនុវត្តថវិកា (ន.ហិរញ្ញវត្ថុ) | 22,516.0 |
| 504 | អនុកម្មវិធីទី៤÷ ការអភិវឌ្ឍធនធានមនុស្សលើវិស័យធនធានទឹក (TSC) | 330.0 |
| 505 | អនុកម្មវិធីទី៥÷ ធ្វើឱ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់សវនដ្ឋាន (ន.សវនកម្មផ្ទៃក្នុង) | 99.0 |
| 506 | អនុកម្មវិធីទី៦÷ កិច្ចការរដ្ឋបាលទូទៅ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ (អាជ្ញាធរទន្លេសាប) | 2,100.0 |
| 507 | អនុកម្មវិធីទី៧÷ ការពង្រឹងស្ថាប័ន និងធនធានមនុស្ស (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | 5,186.0 |
| 508 | អនុកម្មវិធីទី៨÷ ពង្រឹងសេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងការកសាងសមត្ថភាពរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 25,024.0 |

| កូដ កម្មវិធី | តារាង១២÷ គម្រោងចំណាយថវិកាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| **គោលបំណងគោលនយោបាយ÷ "ជំរុញកំណើនកសិកម្មប្រកបដោយភាពប្រកួតប្រជែងផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដីព្រៃឈើ និងជលផល ប្រកបដោយចីរភាព"** | | |
| សរុបរួមចំណាយថវិកា | | 258,327.0 |
| 1 | កម្មវិធីទី១÷ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច | 39,746.6 |
| 101 | អនុកម្មវិធីទី១÷ ការអភិវឌ្ឍដំណាំស្រូវ | 4,056.9 |
| 102 | អនុកម្មវិធីទី២÷ ការអភិវឌ្ឍសាកវប្បកម្ម | 4,711.3 |
| 103 | អនុកម្មវិធីទី៣÷ ការអភិវឌ្ឍដំណាំឧស្សាហកម្ម | 2,384.7 |
| 104 | អនុកម្មវិធីទី៤÷ ការពង្រឹងសេវាគាំទ្រ និងសមត្ថភាពអង្គភាព | 12,521.4 |
| 105 | អនុកម្មវិធីទី៥÷ ការជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិ | 990.2 |
| 106 | អនុកម្មវិធីទី៦÷ ការលើកកម្ពស់គុណភាពការងារពិសោធន៍និងស្រាវជ្រាវកៅស៊ូ | 2,580.0 |
| 107 | អនុកម្មវិធីទី៧÷ ការលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម | 1,512.7 |
| 108 | អនុកម្មវិធីទី៨÷ ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព | 4,661.4 |
| 109 | អនុកម្មវិធីទី៩÷ ការជំរុញផលិតកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច រាជធានី-ខេត្ត | 6,328.0 |
| 2 | កម្មវិធីទី២÷ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ | 14,002.7 |
| 201 | អនុកម្មវិធីទី១÷ ការលើកកម្ពស់ផលិតកម្មសត្វ | 1,260.6 |
| 202 | អនុកម្មវិធីទី២÷ ការលើកកម្ពស់សុខភាពសត្វ | 7,541.9 |
| 203 | អនុកម្មវិធីទី៣÷ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | 2,675.2 |
| 204 | អនុកម្មវិធីទី៤÷ ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ រាជធានី-ខេត្ត | 2,525.0 |
| 3 | កម្មវិធីទី៣÷ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម | 14,532.5 |
| 301 | អនុកម្មវិធីទី១÷ ការគ្រប់គ្រង និងការអភិរក្សធនធានជលផល | 4,116.0 |
| 302 | អនុកម្មវិធីទី២÷ ការអភិវឌ្ឍវារីវប្បកម្ម និងខ្សែច្រវាក់តម្លៃជលផល | 2,090.0 |
| 303 | អនុកម្មវិធីទី៣÷ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | 4,599.5 |
| 304 | អនុកម្មវិធីទី៤÷ ការពង្រឹងការគ្រប់គ្រងធនធានជលផល និងការជំរុញវារីវប្បកម្ម រាជធានី-ខេត្ត | 3,727.0 |

| កូដ កម្មវិធី | តារាង១២÷ គម្រោងចំណាយថវិកាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមកម្មវិធី-អនុកម្មវិធី | ច្បាប់ឆ្នាំ ២០២២ |
|---|---|---|
| 4 | កម្មវិធីទី៤÷ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ | 12,515.5 |
| 401 | អនុកម្មវិធីទី១÷ ការគ្រប់គ្រងព្រៃឈើ | 913.1 |
| 402 | អនុកម្មវិធីទី២÷ ការអភិវឌ្ឍ និងស្រាវជ្រាវព្រៃឈើនិងសត្វព្រៃ | 4,370.1 |
| 403 | អនុកម្មវិធីទី៣÷ ការពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រ | 3,047.3 |
| 404 | អនុកម្មវិធីទី៤÷ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ រាជធានី-ខេត្ត | 4,185.0 |
| 5 | កម្មវិធីទី៥÷ ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស | 177,529.7 |
| 501 | អនុកម្មវិធីទី១÷ ការលើកកម្ពស់ការកសាងនិងការអនុវត្តផែនការគោលនយោបាយនិងវិនិយោគកសិកម្ម (នផក) | 1,316.3 |
| 502 | អនុកម្មវិធីទី២÷ បង្កើនប្រសិទ្ធភាពការរៀបចំ ការគ្រប់គ្រង និងការអនុវត្តថវិកា (នគហ) | 1,207.8 |
| 503 | អនុកម្មវិធីទី៣÷ ការពង្រឹងការគ្រប់គ្រងស្ថាប័ននិងអភិវឌ្ឍន៍ធនធានមនុស្ស (នបុ.អភធ) | 75,425.9 |
| 504 | អនុកម្មវិធីទី៤÷ ការជំរុញសវនកម្មផ្ទៃក្នុង (នសវក) | 222.0 |
| 505 | អនុកម្មវិធីទី៥÷ ការលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពការងារសហប្រតិបត្តិការអន្តរជាតិ (នសហ) | 2,099.5 |
| 506 | អនុកម្មវិធីទី៦÷ ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (ននក) | 260.6 |
| 507 | អនុកម្មវិធីទី៧÷ ការងាររដ្ឋបាល និងការបញ្ជាបយេនឌ័រ | 3,878.6 |
| 508 | អនុកម្មវិធីទី៨÷ ការបង្កើនប្រសិទ្ធភាពការងារអធិការកិច្ច (អគ្គាធិការដ្ឋាន) | 196.2 |
